# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ទសក-ឯកាទសកនិបាត

## ភាគ ៥១

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ទសកនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ និងសុត្រមិនសង្គ្រោះក្នុងបណ្ណាសកៈ

មាន ១៧២ សុត្រ ព្រះអដ្ឋកថាកែសេចក្តី ៤៦ សុត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

# មនោរថបូរណី

## ទសក-ឯកាទសកនិបាត

## ភាគ ៥១

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ទសកនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ និងសូត្រមិនសង្គ្រោះក្នុងបណ្ណាសកៈ

មាន ១១៦ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ៤៦ សូត្រ

# អង្គុត្តរនិកាយ ទសក-ឯកាទសកនិបាត

## រួមមាន

### ៣ បណ្ណាសកៈ មាន ១៥ វគ្គ

### សរុបមាន ១១៦ សូត្រ

### ព្រះអដ្ឋកថាកែសេចក្តី ៤៦ សូត្រ

**តតិយបណ្ណាសកៈ**

| | | |
|---|---|---|
| ១ អានិសង្សវគ្គ | មាន ១២ សូត្រ | អដ្ឋកថាកែសេចក្តី ១២ សូត្រ |
| ២ បច្ចោរោហណិវគ្គមាន ១០ សូត្រ | | អដ្ឋកថាកែសេចក្តី ០៨ សូត្រ |
| ៣ ចារិសុទ្ធិវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី ០១ សូត្រ |
| ៤ សាធុវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី ០១ សូត្រ |
| ៥ អរិយមគ្គវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០០ សូត្រ |

**ចតុត្ថបណ្ណាសកៈ**

| | | |
|---|---|---|
| ១ បុគ្គលវគ្គ | មាន ០១ | អដ្ឋកថាកែសេចក្តី ០០ សូត្រ |
| ២ ជាណុស្សោណិវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី ០៤ សូត្រ |
| ៣ សុន្ទរវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី ០០ សូត្រ |
| ៤ សេដ្ឋវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០០ សូត្រ |
| ៥ សេវិតព្វាសេវិតព្វវគ្គ | | អដ្ឋកថាកែសេចក្តី ០០ សូត្រ |

**បញ្ចមបណ្ណាសកៈ**

| | | |
|---|---|---|
| ១ បឋមវគ្គ | មាន ០៩ | អដ្ឋកថាកែសេចក្តី ០៣ សូត្រ |
| ២ ទុតិយវគ្គ | | អដ្ឋកថាកែសេចក្តី ០០ សូត្រ |
| ៣ តតិយវគ្គ | | អដ្ឋកថាកែសេចក្តី ០០ សូត្រ |

### ឯកាទសកនិបាត

| | | |
|---|---|---|
| ១ និស្សាយវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |
| ២ ទុតិយវគ្គ | មាន ១០ | អដ្ឋកថាកែសេចក្តី ០៧ សូត្រ |

៣ ព្រះសូត្រមិនសង្គ្រោះក្នុងបណ្ណាសកៈ មិនមានអដ្ឋកថាកែសេចក្តី

៤ ពាក្យចុងក្រោយអដ្ឋកថា

# ស្រៈនិងស្រៀយ

# *Signes et accents:*



# ស្រៈពេញតួ
# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | *a* | *ā* | *i* | *i* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក | ខ | គ | ឃ | ង |
| រូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡេម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ຺ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡេម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡាំ Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

## ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

***សុត្ត*** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

***គេយ្យ*** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

***វេយ្យាករណ*** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

***គាថា*** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

***ឧទាន*** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

***ឥតិវុត្តក*** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

***ជាតក*** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

***អព្ភូតធម៌*** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

***វេទល្ល*** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបានទូវសេចក្ដី

រីករាយ និងស្មូវជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធនូៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើង ហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែក ចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បី ជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុក ជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន
រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់
ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ
ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា
បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន
រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង
ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ
វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ
ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ
ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ
ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ
ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី
សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ
ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ
នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ
នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ
ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់
លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស
លោកគ្រូធម្មបណ្ឌិត រស់ សុជាត
លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ឃ្លាត ហ៊ិន ឧបាសក ឆាក់ ម៉ៅ
ឧបាសក ធុំ ធួន ឧបាសក ហុក សីហួត
ឧបាសក ជីម ជំនិត ឧបាសក កើត និត្យ
ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន
ឧបាសក អ៊ឹម វ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត
ឧបាសក សោម រតនៈ ឧបាសក សំ ឆាយ
ឧបាសក ម៉ៅ ជុន ឧបាសក ជា ស៊ីថាន
ឧបាសិកា ជាប់ លឿម ឧបាសិកា ហាយ សាវ៉ាត់
ឧបាសិកា ប៊ុត សុម៉ាលី ឧបាសិកា យស សម្បត្តិ
ឧបាសិកា ពូ ហ៊ាង ឧបាសិកា ប៊ុត សេដាដួង
ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ជុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ចាវ ចាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## ទសកនិបាត តតិយបណ្ណាសកៈ

### អានិសង្សវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា សមណសញ្ញាសូត្រ | ទី ១ | ១ |
| អដ្ឋកថា ពោជ្ឈង្គសូត្រ | ទី ២ | ៣ |
| អដ្ឋកថា មិច្ឆត្តសូត្រ | ទី ៣ | ៤ |
| អដ្ឋកថា សម្មត្តសូត្រ | ទី ៤ | ៥ |
| អដ្ឋកថា អវិជ្ជាវិជ្ជាសូត្រ | ទី ៥ | ៦ |
| អដ្ឋកថា និជ្ជរវត្ថុសូត្រ | ទី ៦ | ៧ |
| អដ្ឋកថា ធោវនសូត្រ | ទី ៧ | ៩ |
| អដ្ឋកថា តិកិច្ឆសូត្រ | ទី ៨ | ១០ |
| អដ្ឋកថា វមនសូត្រ | ទី ៩ | ១១ |
| អដ្ឋកថា និទ្ធមសូត្រ | ទី ១០ | ១២ |
| អដ្ឋកថា អសេក្ខសូត្រ | ទី ១១ | ១៣ |
| អដ្ឋកថា អសេក្ខធម្មសូត្រ | ទី ១២ | ១៤ |


### បច្ចោរោហណិវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា បឋមអធម្មសូត្រ | ទី ១ | ១៥ |
| អដ្ឋកថា ទុតិយអធម្មសូត្រ | ទី ២ | ១៦ |
| អដ្ឋកថា តតិយអធម្មសូត្រ | ទី ៣ | ១៧ |
| អដ្ឋកថា អាជិនសូត្រ | ទី ៤ | ១៩ |
| អដ្ឋកថា សង្គារវសូត្រ | ទី ៥ | ២០ |
| អដ្ឋកថា ឱរិមសូត្រ | ទី ៦ | ២៣ |
| អដ្ឋកថា បឋមបច្ចោរោហណិសូត្រ | ទី ៧ | ២៤ |
| អដ្ឋកថា ទុតិយបច្ចោរោហណិសូត្រ | ទី ៨ | ២៥ |

| | | |
|---|---|---|
| អដ្ឋកថា បុព្វង្គសូត្រ | ទី ៩ មិនមានអដ្ឋកថា | ២៦ |
| អដ្ឋកថា អាសវសូត្រ | ទី ១០ មិនមានអដ្ឋកថា | ២៧ |

## បារិសុទ្ធិវគ្គ ទី ៣

| | | |
|---|---|---|
| អដ្ឋកថា បរិសុទ្ធិសូត្រ | ទី ១ | ២៨ |
| អដ្ឋកថា ឧប្បន្នសូត្រ | ទី ២ មិនមានអដ្ឋកថា | ២៩ |
| អដ្ឋកថា មហាប្ផលសូត្រ | ទី ៣ មិនមានអដ្ឋកថា | ៣០ |
| អដ្ឋកថា បរិយោសានសូត្រ | ទី ៤ មិនមានអដ្ឋកថា | ៣១ |
| អដ្ឋកថា ឯកគ្គសូត្រ | ទី ៥ មិនមានអដ្ឋកថា | ៣២ |
| អដ្ឋកថា បឋមភាវិតសូត្រ | ទី ៦ មិនមានអដ្ឋកថា | ៣៣ |
| អដ្ឋកថា ទុតិយភាវិតសូត្រ | ទី ៧ មិនមានអដ្ឋកថា | ៣៤ |
| អដ្ឋកថា តតិយភាវិតសូត្រ | ទី ៨ មិនមានអដ្ឋកថា | ៣៥ |
| អដ្ឋកថា ចតុត្ថភាវិតសូត្រ | ទី ៩ មិនមានអដ្ឋកថា | ៣៦ |
| អដ្ឋកថា មិច្ឆត្តសូត្រ | ទី ១០ មិនមានអដ្ឋកថា | ៣៧ |
| អដ្ឋកថា សម្មត្តសូត្រ | ទី ១១ មិនមានអដ្ឋកថា | ៣៨ |

## សាធុវគ្គ ទី ៤

| | | |
|---|---|---|
| អដ្ឋកថា សាធុសូត្រ | ទី ១ | ៣៩ |
| អដ្ឋកថា អរិយធម្មសូត្រ | ទី ២ មិនមានអដ្ឋកថា | ៤០ |
| អដ្ឋកថា កុសលសូត្រ | ទី ៣ មិនមានអដ្ឋកថា | ៤១ |
| អដ្ឋកថា អត្ថសូត្រ | ទី ៤ មិនមានអដ្ឋកថា | ៤២ |
| អដ្ឋកថា ធម្មសូត្រ | ទី ៥ មិនមានអដ្ឋកថា | ៤៣ |
| អដ្ឋកថា អាសវធម្មសូត្រ | ទី ៦ មិនមានអដ្ឋកថា | ៤៤ |
| អដ្ឋកថា សាវជ្ជធម្មសូត្រ | ទី ៧ មិនមានអដ្ឋកថា | ៤៥ |
| អដ្ឋកថា តបនិយធម្មសូត្រ | ទី ៨ មិនមានអដ្ឋកថា | ៤៦ |
| អដ្ឋកថា អាចយគាមិធម្មសូត្រ | ទី ៩ មិនមានអដ្ឋកថា | ៤៧ |
| អដ្ឋកថា ទុខុទ្រយធម្មសូត្រ | ទី ១០ មិនមានអដ្ឋកថា | ៤៨ |
| អដ្ឋកថា ទុក្ខវិបាកធម្មសូត្រ | ទី ១១ មិនមានអដ្ឋកថា | ៤៩ |

### អរិយមគ្គវគ្គ ទី ៥

អដ្ឋកថា អរិយមគ្គសូត្រ ទី ១ មិនមានអដ្ឋកថា ៥០
អដ្ឋកថា កណ្ហមគ្គសូត្រ ទី ២ មិនមានអដ្ឋកថា ៥១
អដ្ឋកថា សទ្ធម្មសូត្រ ទី ៣ មិនមានអដ្ឋកថា ៥២
អដ្ឋកថា សប្បុរិសធម្មសូត្រ ទី ៤ មិនមានអដ្ឋកថា ៥៣
អដ្ឋកថា ឧប្បាទេតព្វធម្មសូត្រ ទី ៥ មិនមានអដ្ឋកថា ៥៤
អដ្ឋកថា អាសេវិតព្វធម្មសូត្រ ទី ៦ មិនមានអដ្ឋកថា ៥៥
អដ្ឋកថា ភាវេតព្វធម្មសូត្រ ទី ៧ មិនមានអដ្ឋកថា ៥៦
អដ្ឋកថា ពហុលីកាតព្វធម្មសូត្រ ទី ៨ មិនមានអដ្ឋកថា ៥៧
អដ្ឋកថា អនុស្សរិតព្វធម្មសូត្រ ទី ៩ មិនមានអដ្ឋកថា ៥៨
អដ្ឋកថា សច្ឆិកាតព្វធម្មសូត្រ ទី ១០ មិនមានអដ្ឋកថា ៥៩

## ចតុត្ថបណ្ណាសកៈ

### បុគ្គលវគ្គ ទី ១

អដ្ឋកថា បុគ្គលវគ្គ មិនមានអដ្ឋកថា ៦០

### ជាណុស្សោណិវគ្គ ទី ២

អដ្ឋកថា បឋមបច្ចោរោហណីសូត្រ ទី ១ មិនមានអដ្ឋកថា ៦១
អដ្ឋកថា ទុតិយបច្ចោរោហណីសូត្រ ទី ២ មិនមានអដ្ឋកថា ៦២
អដ្ឋកថា សង្គារវសូត្រ ទី ៣ មិនមានអដ្ឋកថា ៦៣
អដ្ឋកថា ឱរិមសូត្រ ទី ៤ មិនមានអដ្ឋកថា ៦៤
អដ្ឋកថា បឋមអធម្មសូត្រ ទី ៥ មិនមានអដ្ឋកថា ៦៥
អដ្ឋកថា ទុតិយអធម្មសូត្រ ទី ៦ មិនមានអដ្ឋកថា ៦៦
អដ្ឋកថា តតិយអធម្មសូត្រ ទី ៧ មិនមានអដ្ឋកថា ៦៧
អដ្ឋកថា តិរោធសូត្រ ទី ៨ ៦៨
អដ្ឋកថា សបរិក្កមនសូត្រ ទី ៩ ៦៩
អដ្ឋកថា ចុន្ទសូត្រ ទី ១០ ៧០
អដ្ឋកថា ជាណុស្សោណិសូត្រ ទី ១១ ៧១

## សុន្ទះវគ្គ ទី ៣

អដ្ឋកថា សាធុអសាធុសូត្រ ទី ១ មិនមានអដ្ឋកថា ៧៤
អដ្ឋកថា អរិយានរិយធម្មសូត្រ ទី ២ មិនមានអដ្ឋកថា ៧៥
អដ្ឋកថា កុសលាកុសលសូត្រ ទី ៣ មិនមានអដ្ឋកថា ៧៦
អដ្ឋកថា អត្ថានត្ថសូត្រ ទី ៤ មិនមានអដ្ឋកថា ៧៧
អដ្ឋកថា ធម្មាធម្មសូត្រ ទី ៥ មិនមានអដ្ឋកថា ៧៨
អដ្ឋកថា សាសវានាសវសូត្រ ទី ៦ មិនមានអដ្ឋកថា ៧៩
អដ្ឋកថា សាវជ្ជានវជ្ជសូត្រ ទី ៧ មិនមានអដ្ឋកថា ៨០
អដ្ឋកថា តបនិយាតបនិ...សូត្រ ទី ៨ មិនមានអដ្ឋកថា ៨១
អដ្ឋកថា អាចយគាមយ...សូត្រ ទី ៩ មិនមានអដ្ឋកថា ៨២
អដ្ឋកថា ទុក្ខុទ្រយសុខុទ្រ...សូត្រ ទី ១០ មិនមានអដ្ឋកថា ៨៣
អដ្ឋកថា ទុក្ខវិបាកសុខ....សូត្រ ទី ១១ មិនមានអដ្ឋកថា ៨៤

## សេដ្ឋវគ្គ ទី ៤

អដ្ឋកថា អរិយមគ្គានរិយមគ្គសូត្រ ទី ១ មិនមានអដ្ឋកថា ៨៥
អដ្ឋកថា កណ្ហមគ្គសុក្កមគ្គសូត្រ ទី ២ មិនមានអដ្ឋកថា ៨៦
អដ្ឋកថា សទ្ធម្មាសទ្ធម្មសូត្រ ទី ៣ មិនមានអដ្ឋកថា ៨៧
អដ្ឋកថា សប្បុរិសធម្មា...សូត្រ ទី ៤ មិនមានអដ្ឋកថា ៨៨
អដ្ឋកថា ឧប្បាទេតព្វា...សូត្រ ទី ៥ មិនមានអដ្ឋកថា ៨៩
អដ្ឋកថា អាសេវិតព្វានា...សូត្រ ទី ៦ មិនមានអដ្ឋកថា ៩០
អដ្ឋកថា ភាវេតព្វាភាវេ...សូត្រ ទី ៧ មិនមានអដ្ឋកថា ៩១
អដ្ឋកថា ពហុលីកាតព្វា...សូត្រ ទី ៨ មិនមានអដ្ឋកថា ៩២
អដ្ឋកថា អនុស្សរិតព្វាន...សូត្រ ទី ៩ មិនមានអដ្ឋកថា ៩៣
អដ្ឋកថា សច្ឆិកាតព្វាសច្ឆិ...សូត្រ ទី ១០ មិនមានអដ្ឋកថា ៩៤

## សេវិតព្វាសេវិតព្វវគ្គ ទី ៥

អដ្ឋកថា សេវិតព្វាសេវិតព្វវគ្គ ទី ៥ មិនមានអដ្ឋកថា ៩៥

# បញ្ចមបណ្ណាសកៈ


**បឋមវគ្គ ទី ១**

អដ្ឋកថា យថាភតសូត្រ ទី ១ មិនមានអដ្ឋកថា ៩៦
អដ្ឋកថា មាតុគាមសូត្រ ទី ២ មិនមានអដ្ឋកថា ៩៧
អដ្ឋកថា បឋមឧបាសិកាសូត្រ ទី ៣ មិនមានអដ្ឋកថា ៩៨
អដ្ឋកថា ទុតិយឧបាសិកាសូត្រ ទី ៤ មិនមានអដ្ឋកថា ៩៩
អដ្ឋកថា ធម្មបរិយាយសូត្រ ទី ៥ ១០០
អដ្ឋកថា បឋមកម្មសូត្រ ទី ៦ ១០២
អដ្ឋកថា ទុតិយកម្មសូត្រ ទី ៧ មិនមានអដ្ឋកថា ១០៤
អដ្ឋកថា តតិយកម្មសូត្រ ទី ៨ ១០៥
អដ្ឋកថា ព្រាហ្មណសូត្រ ទី ៩ មិនមានអដ្ឋកថា ១០៨

**ទុតិយវគ្គ ទី ២**

អដ្ឋកថា ទុតិយវគ្គ មិនមានអដ្ឋកថា ១០៩

**តតិយវគ្គ ទី ៣** មិនមានអដ្ឋកថា ១១៧

## ឯកាទសកនិបាត

**និស្សាយវគ្គ ទី ១**

អដ្ឋកថា កិមត្ថិយសូត្រ ទី ១ ១២៧
អដ្ឋកថា ចេតនាសូត្រ ទី ២ ១២៨
អដ្ឋកថា បឋមឧបនិសាសូត្រ ទី ៣ ១២៩
អដ្ឋកថា ទុតិយឧបនិសាសូត្រ ទី ៤ ១៣០
អដ្ឋកថា តតិយឧបនិសាសូត្រ ទី ៥ ១៣១
ព្រះអដ្ឋកថាកែសេចក្តីមក្នុង ៥ សូត្រ ខាងលើ ១៣២
អដ្ឋកថា ព្យសនសូត្រ ទី ៦ ១៣៣
អដ្ឋកថា សញ្ញាសូត្រ ទី ៧ ១៣៤
អដ្ឋកថា មនសិការសូត្រ ទី ៨ ១៣៥

| | | | |
|---|---|---|---|
| អដ្ឋកថា អសេក្ខសូត្រ | ទី ៩ | | ១៣៦ |
| អដ្ឋកថា មោរនិវាបនសូត្រ | ទី ១០ | | ១៣៩ |
| **ទុតិយវគ្គ ទី ២** | | | |
| អដ្ឋកថា បឋមមហានាមសូត្រ | ទី ១ | | ១៤១ |
| អដ្ឋកថា ទុតិយមហានាមសូត្រ | ទី ២ | | ១៤២ |
| អដ្ឋកថា នន្ទិយសូត្រ | ទី ៣ | | ១៤៣ |
| អដ្ឋកថា សុភូតិសូត្រ | ទី ៤ | | ១៤៤ |
| អដ្ឋកថា មេត្តាសូត្រ | ទី ៥ | | ១៤៥ |
| អដ្ឋកថា ឧសមសូត្រ | ទី ៦ | | ១៥០ |
| អដ្ឋកថា គោបាលកសូត្រ | ទី ៧ | | ១៥៨ |
| អដ្ឋកថា បឋមសមាធិសូត្រ | ទី ៨ | មិនមានអដ្ឋកថា | ១៧៨ |
| អដ្ឋកថា ទុតិយសមាធិសូត្រ | ទី ៩ | មិនមានអដ្ឋកថា | ១៧៩ |
| អដ្ឋកថា តតិយសមាធិសូត្រ | ទី ១០ | មិនមានអដ្ឋកថា | ១៨០ |
| អដ្ឋកថា ចតុត្ថសមាធិសូត្រ | ទី ១១ | មិនមានអដ្ឋកថា | ១៨១ |

**ព្រះសូត្រមិនសង្គ្រោះដោយបណ្ណាសកៈ** ១៨២

**ពាក្យចុងក្រោយអដ្ឋកថា** ១៨៣

# តតិយបណ្ណាសកៈ

# សមណសញ្ញាវគ្គវណ្ណនាទី ១

## អដ្ឋកថា សមណសញ្ញាសូត្រទី ១

### *ភិក្ខុចម្រើនសមណសញ្ញា ៣ ប្រការ*

### *រមែងញ៉ាំងធម៌ ៧ ប្រការឲ្យបរិបូរណ៍*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមណសញ្ញាសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា* ***សមណសញ្ញា*** *បានដល់ សេចក្តីសម្គាល់ដែលកើតឡើងដល់សមណៈទាំងឡាយ ។ បទថា* ***សតតការី*** *(ជាអ្នកមានប្រក្រតីធ្វើជាប់តគ្នា) បានដល់ ធ្វើមិនមានចន្លោះ ។ បទថា* ***អព្យាបជ្ឈោ*** *(ជាអ្នកមិនព្យាបាទ) បានដល់ គ្មានទុក្ខ ។ បទថា* ***ឥច្ចត្ថន្តិស្ស ហោតិ*** *(ជាអ្នកមានការពិចារណា... ថា បច្ច័យទាំងនេះមានប្រយោជន៍ដូច្នេះ ហើយទើបបរិភោគ) សេចក្តីថា សមណសញ្ញា រមែងមានដល់ភិក្ខុនោះ ក្នុងបច្ច័យជាគ្រឿងចិញ្ចឹមជីវិត យ៉ាងនេះថា ទាំងនេះជាបច្ច័យដើម្បីវត្ថុនេះ ។*

*អធិប្បាយថា ភិក្ខុបរិភោគបច្ច័យដែលពិចារណាហើយ ។*

ចប់អដ្ឋកថា សមណសញ្ញាសូត្រទី ១

# អដ្ឋកថា ពោជ្ឈង្គសូត្រទី ២

*ភិក្ខុចម្រើនពោជ្ឈង្គ ៧ ហើយ*

*រមែងញ៉ាំងវិជ្ជា ៣ ឲ្យបរិបូរណ៍*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពោជ្ឈង្គសូត្រទី ២ ដូចតទៅនេះ ៖*

[២] *អដ្ឋកថាពោជ្ឈង្គសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ពោជ្ឈង្គសូត្រទី ២

# អដ្ឋកថា មិច្ឆត្តសូត្រទី ៣

## *ភិក្ខុអាស្រ័យមិច្ឆត្តៈ ១០ ទើបឃ្លាតចាកសួគ៌ និងមគ្គផល*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មិច្ឆត្តសូត្រទី ៣ ដូចតទៅនេះ ៖*

[៣] *បទថា* ***វិរាធនា ហោតិ*** *(ទើបមានការឃ្លាត) សេចក្តីថា ឃ្លាតចាកសួគ៌ និងមគ្គ រមែងមាន ។ បទថា* ***នោ អារាធនា*** *(មិនមានការសម្រេច) សេចក្តីថា សេចក្តីសម្រេចផលក៏មិនមាន ការធ្វើឲ្យបរិបូរណ៍ ក៏មិនមាន ។ បទថា* ***បហោតិ*** *(រមែងមាន) ប្រែថា រមែងប្រព្រឹត្តទៅ ។*

ចប់អដ្ឋកថា មិច្ឆត្តសូត្រទី ៣

# អដ្ឋកថា សម្មត្តសូត្រទី ៤

## *ភិក្ខុអាស្រ័យសម្មត្តៈ ១០ ទើបសម្រេចសួគ៌ និងមគ្គផល*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សម្មត្តសូត្រទី ៤ ដូចតទៅនេះ ៖*

*[៤] បទថា **យថាទិដ្ឋិសមត្តំ សមាទិន្នំ** (សមាទាន... ឲ្យបរិបូរ តាមការឃើញយ៉ាងណាហើយ) បានដល់ សមាទានឲ្យបរិបូរណ៍តម្កល់ទុកទាំងអស់ តាមសមគួរដល់ទិដ្ឋិ ។ បទថា **ចេតនា** (ចេតនា) បានដល់ ចេតនាដែលកើតក្នុងទ្វារទាំង ៣ ដែលប្រកាន់មាំហើយ ។ បទថា **បត្ថនា** (សេចក្ដីប្រាថ្នា) បានដល់ សេចក្ដីប្រាថ្នា ដែលប្រាថ្នាទុកយ៉ាងនេះថា សូមឲ្យយើងគប្បីជាយ៉ាងនេះ ។ បទថា **បណិធិ** (ការតាំងចិត្ត) បានដល់ ការតាំងចិត្តថា យើងនឹងជាទេវតា ឬទេវតាមួយអង្គ ។ បទថា **សង្ខារា** (សង្ខារ) បានដល់ សង្ខារដែលប្រកបព្រមហើយ ។*

ចប់អដ្ឋកថា សម្មត្តសូត្រទី ៤

# អដ្ឋកថា អវិជ្ជាវិជ្ជាសូត្រទី ៥

## ពោលពីអវិជ្ជា និងវិជ្ជា

គប្បីជ្រាបវិនិច្ឆ័យក្នុង អវិជ្ជាវិជ្ជាសូត្រទី ៥ ដូចតទៅនេះ ៖

[៥] អវិជ្ជា ឈ្មោះថា ជាប្រធាន ព្រោះអត្ថថា ដំណើរទៅមុន ។ បទថា អន្វទេវ (ជារបស់មានមកតាមអវិជ្ជានោះ) បានដល់ ជាប់តាម អវិជ្ជានោះទៅ ។

ចប់អដ្ឋកថា អវិជ្ជាសូត្រទី ៥

# អដ្ឋកថា និជ្ជរវត្ថុសូត្រទី ៦

## *ហេតុនៃការវិនាសទៅ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និជ្ជរវត្ថុសូត្រទី ៦ ដូចតទៅនេះ ៖*

*[៦] បទថា **និជ្ជរវត្ថូនិ** ប្រែថា ហេតុនៃការវិនាស ។ បទថា **មិច្ឆាទិដ្ឋិ និជ្ជិណ្ណា ហោតិ** (រមែងមានការឃើញខុសវិនាសទៅ) សេចក្តីថា មិច្ឆាទិដ្ឋិដែលដល់នូវសេចក្តីសាបសូន្យទៅ សូម្បីព្រោះវិបស្សនាយ៉ាងទាប ដែលលោកលះបានហើយយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី លោកទើបកាន់យកទៀត ។ ឆ្លើយថា ព្រោះមិច្ឆាទិដ្ឋិនោះ លោកដកមិនទាន់ដាច់ ។ ព្រោះថា មិច្ឆាទិដ្ឋិ សូម្បីដកមិនទាន់ដាច់ដោយវិបស្សនាក៏ពិត តែកាលមគ្គកើតឡើង ក៏ដកមិច្ឆាទិដ្ឋិបានជាសមុច្ឆេទ គឺ មិនឲ្យកើតឡើងទៀត ព្រោះដូច្នោះ លោកទើបកាន់យកទៀត ។ ក្នុងគ្រប់បទក៏គប្បីជ្រាបតាមន័យនេះឯង ។*

*មួយទៀត ក្នុងសូត្រនេះ ធម៌ ៦៤ រមែងដល់នូវសេចក្តីចម្រើនបរិបូរណ៍ ព្រោះសម្មាវិមុត្តិជាបច្ច័យ គឺ ធម៌ ៦៤ បានដល់ ក្នុងខណៈនៃ*

សោតាបត្តិមគ្គចិត្ត សទ្ធិន្ទ្រិយ រមែងបរិបូរ ព្រោះអត្ថថា បង្អោនចិត្តទៅ វីរិយិន្ទ្រិយបរិបូរ ព្រោះអត្ថថា ផ្គងចិត្ត សតិន្ទ្រិយបរិបូរ ព្រោះអត្ថថា ចូលទៅតាំងទុក សមាធិន្ទ្រិយបរិបូរ ព្រោះអត្ថថា មិនរវើរវាយ បញ្ញិ-ន្ទ្រិយបរិបូរ ព្រោះអត្ថថា ឃើញ មនិន្ទ្រិយបរិបូរ ព្រោះអត្ថថា ដឹងច្បាស់ សោមនស្សិន្ទ្រិយបរិបូរ ព្រោះអត្ថថា ហូរជ្រួតជ្រាបទៅ ជីវិតិន្ទ្រិយបរិបូរ ព្រោះអត្ថថា មានសន្តតិដែលបន្តគ្នាប្រព្រឹត្តទៅជាធំ ។ល។ ក្នុងខណៈនៃ អរហត្តផលចិត្ត សទ្ធិន្ទ្រិយបរិបូរ ព្រោះអត្ថថា បង្អោនចិត្តជឿ ។ល។ ជីវិតិន្ទ្រិយបរិបូរ ព្រោះអត្ថថា មានសន្តតិដែលបន្តគ្នាប្រព្រឹត្តទៅជាធំ ។ ធម៌ ៦៤ គឺ មគ្គ ៤ ផល ៤ ក្នុងមួយៗ មាន ៨ រមែងដល់នូវសេចក្តី បរិបូរ ដោយប្រការដូចដែលបានពោលមក ដូច្នេះ ។

ចប់អដ្ឋកថា និដ្ឋវត្ថុសូត្រទី ៦

# អដ្ឋកថា ធោវនសូត្រទី ៧

## *ការលាងរបស់ព្រះអរិយៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ធោវនសូត្រទី ៧ ដូចតទៅនេះ ៖*

[៧] *បទថា **ធោវនំ** (ការលាង) បានដល់ ការលាងឆ្អឹង ។ ពិតហើយ ក្នុងជនបទនោះ មនុស្សទាំងឡាយ កាលញាតិស្លាប់ក៏មិនដុត តែជីករណ្តៅកប់ ។ លុះកន្លងហើយ ទើបនាំឆ្អឹងរបស់ញាតិទាំងនោះមកលាង ហើយលើកឡើងដាក់រៀងគ្នា តាំងពិធីបូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម ក្នុងវេលានក្ខត្តឫក្ស ក៏នាំឆ្អឹងទាំងនោះមក ហើយស្រែកយំ រៀបរាប់ តពីនោះក៏លេងនក្ខត្តឫក្ស ។*

ចប់អដ្ឋកថា ធោវនសូត្រទី ៧

# អដ្ឋកថា តិកិច្ឆសូត្រទី ៨

## ថ្នាំបញ្ចុះរបស់ព្រះអរិយៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង តិកិច្ឆសូត្រទី ៨ ដូចតទៅនេះ ៖

[៨] បទថា *វិរេចនំ* (ថ្នាំបញ្ចុះ) បានដល់ ថ្នាំបញ្ចុះទោសចេញ ។ បទថា *វិរិតា ហោតិ* (បន្ទោបង់ចេញ) បានដល់ កម្ចាត់ចេញ ។

ចប់អដ្ឋកថា តិកិច្ឆសូត្រទី ៨

# អដ្ឋកថា វមនសូត្រទី ៩

## *ថ្នាំក្អួតរបស់ព្រះអរិយៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វមនសូត្រទី ៩ ដូចតទៅនេះ ៖*

[៩] *បទថា* ***វមនំ*** *ប្រែថា ថ្នាំក្អួត ។*

ចប់អដ្ឋកថា វមនសូត្រទី ៩

# អដ្ឋកថា និទ្ធមសូត្រទី ១០

## *ធម៌ដែលបុគ្គលគប្បីកម្ចាត់ចេញ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និទ្ធមសូត្រទី ១០ ដូចតទៅនេះ ៖*

[១០] *បទថា និទ្ធមនិយា ប្រែថា ដែលបុគ្គលគប្បីកម្ចាត់ចេញ ។*

ចប់អដ្ឋកថា និទ្ធមសូត្រទី ១០

# អដ្ឋកថា អសេក្ខសូត្រទី ១១

## *ហេតុដែលហៅថា ព្រះអសេក្ខៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសេក្ខសូត្រទី ១១ ដូចតទៅនេះ ៖*

[១១] *ព្រះមានព្រះភាគត្រាស់ សម្មាទិដ្ឋិតែម្យ៉ាងថា សម្មាញាណ ដើម្បីសេចក្តីបរិបូរណ៍នៃអដ្ឋមគ្គ ធម៌ គឺ ព្រះអរហត្តផលសូម្បីទាំងអស់នោះ ក៏ដូច្នោះ ។ សូម្បីបច្ចវេក្ខណញ្ញាណ ក៏ត្រាស់ថា អសេក្ខៈ ព្រោះអសេក្ខធម៌ ដំណើរទៅហើយ ។*

ចប់អដ្ឋកថា អសេក្ខសូត្រទី ១១

# អដ្ឋកថា អសេក្ខធម្មសូត្រទី ១២

## *ធម៌របស់ព្រះអសេក្ខ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសេក្ខធម្មសូត្រទី ១២ ដូចតទៅនេះ ៖*

[១២] *បទថា អសេក្ខិយា (ដែលជារបស់ព្រះអសេក្ខៈ) បានដល់ អសេក្ខៈតែម្យ៉ាង ឬជារបស់ព្រះអសេក្ខៈ គឺ ទ្រង់ត្រាស់ព្រះទីណាស្រេច ប៉ុណ្ណោះ ទុកក្នុងសូត្រនេះ ។*

ចប់អដ្ឋកថា អសេក្ខធម្មសូត្រទី ១២

## ចប់សមណវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១២ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១១ សូត្រ

# បច្ចោរោហណិវគ្គវណ្ណនាទី ២

## អដ្ឋកថា បឋមអធម្មសូត្រទី ១

*គួរជ្រាបទាំងវត្ថុដែលមិនមែនជាធម៌*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអធម្មសូត្រទី ១ ដូចតទៅនេះ ៖*

[១៣] *ព្រះមានព្រះភាគត្រាស់បុច្ឆា និងវិសជ្ជនាផ្សេងគ្នា ។ ចំណែកអធម្មសូត្រទី ២ ទ្រង់ត្រាស់រួមគ្នា ។*

ចប់អដ្ឋកថា បឋមអធម្មសូត្រទី ១

# អដ្ឋកថា ទុតិយអធម្មសូត្រទី ២

## បុគ្គលគួរបដិបត្តិតាមវត្ថុដែលជាធម៌

## និងតាមវត្ថុដែលជាប្រយោជន៍

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអធម្មសូត្រទី ២ ដូចតទៅនេះ ៖*

[១៤] *អធម្មសូត្រទី ២ ទ្រង់ត្រាស់រួមគ្នា ។*

ចប់អដ្ឋកថា ទុតិយអធម្មសូត្រទី ២

# អដ្ឋកថា តតិយអធម្មសូត្រទី ៣

## *ព្រះអានន្ទសម្ដែងចែកធម៌ដែល*

## *ព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយពិស្ដារ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយអធម្មសូត្រទី ៣ ដូចតទៅនេះ ៖*

[១៥] *បទថា **ឧទ្ទេសំ ឧទ្ទិសិត្វា** (ទ្រង់សម្ដែងឧទ្ទេស) បានដល់តាំងបទមាតិកា ។ បទថា **សត្ថុចេវ សំវណ្ណិតោ** (ដែលព្រះសាស្ដាទ្រង់សរសើរហើយ) សេចក្ដីថា ព្រះអានន្ទ ដែលព្រះសាស្ដាអ្នកទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ក្នុងឋានៈ ៥ ប្រការ ទ្រង់សរសើរហើយ ។ បទថា **សម្ភាវិតោ** (សរសើរហើយ) សេចក្ដីថា ដែលពួកសព្រហ្មចារីជាបណ្ឌិត សរសើរហើយ ដោយការសរសើរព្រោះគុណ ។ បទថា **បហោតិ** ប្រែថា រមែងអាច ។*

*បទថា **អតិសិត្វា** ប្រែថា កន្លងហួស ។ បទថា **ជានំ ជានាតិ** ប្រែថា ទ្រង់ដឹងធម៌ដែលគួរដឹង ។ បទថា **បស្សំ បស្សតិ** ប្រែថា ទ្រង់ឃើញធម៌ដែលគួរឃើញ ។ បទថា **ចក្ខុភូតោ** (ទ្រង់មានព្រះចក្ខុ) បាន*

ដល់ ទ្រង់មានចក្ខុកើតហើយ ។ បទថា ញាណភូតោ (មានព្រះញាណ) បានដល់ ទ្រង់មានព្រះញាណកើតហើយ ។ បទថា ធម្មភូតោ (មានធម៌) បានដល់ ទ្រង់មានធម៌កើតហើយ ។ បទថា ព្រហ្មភូតោ (ទ្រង់ជាបុគ្គលដ៏ប្រសើរ) បានដល់ ទ្រង់ជាបុគ្គលប្រសើរបំផុតជាសភាព ។ បទថា វត្តា (ទ្រង់ជាអ្នកប្រាប់) បានដល់ ទ្រង់អាចត្រាស់ប្រាប់ ។ បទថា បវត្តា (ទ្រង់ជាអ្នកប្រៀនប្រដៅ) បានដល់ ទ្រង់អាចឲ្យអ្នកដទៃដំណើរទៅ ។ បទថា អត្ថស្ស និន្នេតា (ទ្រង់សម្តែងប្រយោជន៍) បានដល់ ទ្រង់នាំអត្ថមកសម្តែង ។ បទថា យថា នោ ភគវា (ព្រះមានព្រះភាគ... ដល់ខ្ញុំព្រះអង្គទាំងឡាយ ដោយប្រការណា) សេចក្តីថា ព្រះមានព្រះភាគទ្រង់ព្យាករណ៍ដល់ពួកយើងដោយប្រការណា ។

ចប់អដ្ឋកថា តតិយអធម្មសូត្រទី ៣

# អដ្ឋកថា អាជិនសូត្រទី ៤

## ពោលដោយ អាជិនបរិញ្វាជក

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាជិនសូត្រទី ៤ ដូចតទៅនេះ ៖*

[១៦] *បទថា* ***អាជិនោ*** *(អាជិនៈ) បានដល់ បរិញ្វាជកមានឈ្មោះយ៉ាងនេះ ។ បទថា* ***ចិត្តដ្ឋានសតានិ*** *ប្រែថា ចិត្តុប្បាទ ១០០ ដួង ។ បទថា* ***យេហិ*** *បានដល់ ប្រកបហើយដោយចិត្តុប្បាទ ១០០ ដួងណា ។ បទថា* ***ឧបារទ្ធាវ ជានន្តិ ឧបារទ្ធស្មា*** *(អ្នកត្រូវសង្កត់សង្កិនហើយ ដឹងខ្លួនថា ត្រូវគេសង្កត់សង្កិន) សេចក្តីថា អន្យតិរ្ថិយដែលខុសហើយ ត្រូវសង្កត់សង្កិនហើយ រមែងដឹងយ៉ាងនេះថា យើងជាអ្នកខុសហើយ យើងជាអ្នកត្រូវសង្កត់សង្កិនហើយ យើងត្រូវគេលើកទោសឡើងហើយ ដូច្នេះ ។ បទថា* ***បណ្ឌិតវត្ថូនិ*** *(ហេតុនៃភាពជាបណ្ឌិត) បានដល់ ជាហេតុដើម្បីប្រយោជន៍ដល់ភាពជាបណ្ឌិត ។*

ចប់អដ្ឋកថា អាជិនសូត្រទី ៤

# អដ្ឋកថា សគារវសូត្រទី ៥

## ពោលដោយត្រើយអាយ និងត្រើយនាយ

*គប្បីជ្រាបវិនិច្ឆ័យក្នុង សគារវសូត្រទី ៥ ដូចតទៅនេះ ៖*

[១៧] *បទថា* **ឱរិមំ តីរំ** *(ជាត្រើយនេះ) បានដល់ លោកិយៈ ឈ្មោះថា ត្រើយអាយ ។ បទថា* **បារិមំ តីរំ** *(ជាត្រើយនាយ) បានដល់ លោកុត្តរៈ ឈ្មោះថា ត្រើយនាយ ។*

*បទថា* **បារគាមិនោ** *(អ្នកទៅដល់ត្រើយនាយ) បានដល់ អ្នកដល់ព្រះនិព្វាន ។ បទថា* **តីរមេវានុធាវតិ** *(ស្ទុះទៅតាមត្រើយនេះ) បានដល់ ស្ទុះទៅកាន់ត្រើយ គឺ សក្កាយទិដ្ឋិ ។ បទថា* **ធម្មេ ធម្មានុវត្តិនោ** *(ប្រព្រឹត្តតាមធម៌ ក្នុងធម៌) សេចក្ដីថា ប្រព្រឹត្តធម៌តាមសមគួរដល់លោកុត្តរធម៌ ៩ ដែលត្រាស់ទុកហើយដោយប្រពៃ បានដល់ ប្រព្រឹត្តតាមវត្តបដិបត្តិខាងដើមព្រមទាំងសីល ដែលសមគួរដល់ធម៌នោះ ។ បទថា* **មច្ចុធេយ្យំ សុទុត្តរំ** *(ធ្លងផុតវដ្ដៈដែលជាអន្ទាក់មារ ដែលធ្លងផុតដោយលំបាក) បានដល់ ធ្លងវដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាទីតាំងនៃមច្ចុមារ ដែល*

ធ្វើបានសែនលំបាក ។ បទថា **បារមេស្សន្តិ (នឹងដល់ត្រើយនាយ)** បានដល់ នឹងដល់ព្រះនិព្វាន ។ បទថា **ឱកា អនោកមាគម្ម (ចេញចាកអាល័យ អាស្រ័យធម៌ដែលមិនមានអាល័យ)** បានដល់ អាស្រ័យវិវដ្ដៈចាកវដ្ដៈ ។ បទថា **វិវេកេ យត្ថ ទូរមំ (ក្នុងវិវេកដែលត្រេកអរបានលំបាក)** ប្រែថា គប្បីប្រាថ្នាសេចក្ដីត្រេកអរក្នុងកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ដែលជាទីត្រេកអរដ៏ក្រៃលែងបានលំបាក ។ បទថា **ហិត្វា កាមេ (លះបង់កាមទាំងឡាយហើយ)** បានដល់ លះបង់កាមសូម្បីទាំងពីរ ។ បទថា **អកិញ្ចនោ (ជាអ្នកមិនមានកង្វល់)** បានដល់ មិនមានកិលេសជាគ្រឿងកង្វល់ ។ បទថា **អាទានបដិនិស្សគ្គេ (ក្នុងនិព្វានជាទីលះបង់សេចក្ដីប្រកាន់មាំ)** បានដល់ ក្នុងព្រះនិព្វាន ពោលគឺ ការលះបង់សេចក្ដីប្រកាន់មាំ ។ បទថា **អនុបាទាយ យេ រតា (មិនប្រកាន់មាំហើយត្រេកអរ)** សេចក្ដីថា ជនពួកណាមិនប្រកាន់សូម្បីវត្ថុណាៗ ដោយឧបាទាន ៤ ហើយត្រេកអរក្រៃលែង ។ បទថា **បរិនិព្វុតា (រលត់ស្និទ្ធហើយ)** បានដល់ ជនពួកនោះ គប្បីជ្រាបថា ឈ្មោះថា បរិនិព្វានហើយ

*ដោយបរិនិព្វានដែលរកបច្ច័យមិនបាន ។*

ចប់អដ្ឋកថា សការវសូត្រទី ៥

# អដ្ឋកថា ឱរិមសូត្រទី ៦

## *ពោលដោយត្រើយអាយ និងត្រើយនាយ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឱរិមសូត្រទី ៦ ដូចតទៅនេះ ៖*

[១៨] *ទ្រង់ត្រាស់សម្តែងដល់ភិក្ខុទាំងឡាយ ។*

ចប់អដ្ឋកថា ឱរិមសូត្រទី ៦

# អដ្ឋកថា បឋមបច្ចោរោហណិសូត្រទី ៧

## *វិធីជំរះបាបរបស់ព្រះអរិយៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមបច្ចោរោហណិសូត្រទី ៧ ដូចតទៅនេះ ៖*

[១៩] *បទថា* ***បច្ចោរោហណី*** *(វិធីជំរះបាប) បានដល់ ការបណ្តេតបាប ។ បទថា* ***បត្តរិត្វា*** *បានដល់ ក្រាល ។ បទថា* ***អន្តរា ច វេលំ អន្តរា ច អគ្យាគារំ*** *ប្រែថា រវាងគំនរខ្សាច់ និងរោងភ្លើង ។*

ចប់អដ្ឋកថា បឋមបច្ចោរោហណិសូត្រទី ៧

# អដ្ឋកថា ទុតិយបច្ចោរោហណិសូត្រទី ៨

## *វិធីជំរះបាបរបស់ព្រះអរិយៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយបច្ចោរោហណីសូត្រទី ៨ ដូចតទៅនេះ ៖*

[២០] *ទុតិយបច្ចោរោហណី ទ្រង់សម្តែងដល់ភិក្ខុសង្ឃ ។ ពាក្យដ៏សេសគ្រប់កន្លែង មានសេចក្តីងាយហើយនោះឯង ។*

ចប់អដ្ឋកថា ទុតិយបច្ចោរោហណិសូត្រទី ៨

# អដ្ឋកថា បុព្វង្គសូត្រទី ៩

## សម្មាទិដ្ឋិជានិមិត្តខាងដើម នៃកុសលធម៌ទាំងឡាយ

គប្បីជ្រាបវិនិច្ឆ័យក្នុង បុព្វង្គសូត្រទី ៩ ដូចតទៅនេះ ៖

[២១] ក្នុងព្រះសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ ។

ចប់អដ្ឋកថា បុព្វង្គសូត្រទី ៩

# អដ្ឋកថា អាសវសូត្រទី ១០

## *បុគ្គលចម្រើនធម៌ ១០ ប្រការឲ្យច្រើន រមែងអស់អាសវៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាសវសូត្រទី ១០ ដូចតទៅនេះ ៖*

[២២] *ក្នុងព្រះសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា អាសវសូត្រទី ១០

## ចប់បច្ចោរោហណីវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# បរិសុទ្ធិវគ្គវណ្ណនាទី ៣

## អដ្ឋកថា បរិសុទ្ធិសូត្រទី ១

*ធម៌ ១០ វៀរចាកសុគតវិន័យហើយ*

*រមែងមិនមាន*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិសុទ្ធិសូត្រទី ១ ដូចតទៅនេះ ៖*

[២៣] *បទថា **បរិសុទ្ធា** (បរិសុទ្ធ) បានដល់ គ្មានមន្ទិល ។ បទថា **បរិយោទាតា** បានដល់ ផូរផង់ ។*

ចប់អដ្ឋកថា បរិសុទ្ធិសូត្រទី ១

# អដ្ឋកថា ឧប្បន្នសូត្រទី ២

## *ធម៌ ១០ ប្រការ វៀរចាកសុគតវិន័យហើយ រមែងមិនកើតឡើង*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧប្បន្នសូត្រទី ២ ដូចតទៅនេះ ៖*

[២៤] *សូត្រទី ២ ជាដើម មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ឧប្បន្នសូត្រទី ២

# អដ្ឋកថា មហាប្ចូលសូត្រទី ៣

## *ធម៌ ១០ ដែលមានផលច្រើន មានអានិសង្សច្រើន*

## *វៀរចាកសុគតវិន័យហើយ រមែងមិនមាន*

[២៥] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា មហាប្ចូលសូត្រទី ៣

# អដ្ឋកថា បរិយោសានសូត្រទី ៤

## *ធម៌ ១០ ប្រការ កម្ចាត់រាគៈ ទោសៈ មោហៈ ជាទីបំផុត*

[២៦] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា បរិយោសានសូត្រទី ៤

# អដ្ឋកថា ឯកន្តសូត្រទី ៥

## *ធម៌ ១០ ប្រការប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង*

[២៧] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា ឯកន្តសូត្រទី ៥

# អដ្ឋកថា បឋមភាវិតសូត្រទី ៦

## *ធម៌ ១០ ដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ*

## *ធម៌មិនទាន់កើត រមែងកើតឡើង*

[២៨] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា បឋមភាវិតសូត្រទី ៦

# អដ្ឋកថា ទុតិយភាវិតសូត្រទី ៧

## *ធម៌ ១០ ដែលមានផលច្រើន មានអានិសង្សច្រើន*

[២៩] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា ទុតិយភាវិតសូត្រទី ៧

# អដ្ឋកថា តតិយភាវិតសូត្រទី ៨

## *ធម៌ ១០ ប្រការដែលដែលបុគ្គលចម្រើនហើយ*

## *រមែងកម្ចាត់រាគៈ ទោសៈ មោហៈបាន*

[៣០] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា តតិយភាវិតសូត្រទី ៨

# អដ្ឋកថា ចតុត្ថភាវិតសូត្រទី ៩

## *ធម៌ ១០ ប្រការ ដែលបុគ្គលចម្រើនហើយ*

## *រមែងប្រព្រឹត្តទៅដើម្បីត្រាស់ដឹង*

[៣១] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា ចតុត្ថភាវិតសូត្រទី ៩

# អដ្ឋកថា មិច្ឆត្តសូត្រទី ១០

## *មិច្ឆត្តធម៌ ១០ ប្រការ*

[៣២] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា មិច្ឆត្តសូត្រទី ១០

# អដ្ឋកថា សម្មត្តសូត្រទី ១១

## *សម្មត្តធម៌ ១០ ប្រការ*

[៣៣] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា សម្មត្តសូត្រទី ១១

## ចប់ចារិសុទ្ធិវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០១ សូត្រ

# សាធុវគ្គវណ្ណនាទី ៤

## អដ្ឋកថា សាធុសូត្រទី ១

### *វត្ថុល្អ និងមិនល្អ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាធុសូត្រទី ១ ដូចតទៅនេះ ៖*

[៣៤] *បទថា សាធុំ (វត្ថុល្អ) បានដល់ គឺចម្រើន ស្អាតល្អ ។*

ចប់អដ្ឋកថា សាធុសូត្រទី ១

# អដ្ឋកថា អរិយធម្មសូត្រទី ២

## *អរិយធម៌ និងអនរិយធម៌*

[៣៥] *មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា អរិយធម្មសូត្រទី ២

# អដ្ឋកថា កុសលសូត្រទី ៣

## វត្ថុល្អ និងមិនល្អ

[៣៦] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា កុសលសូត្រទី ៣

# អដ្ឋកថា អត្ថសូត្រទី ៤

## វត្ថុជាប្រយោជន៍ និងមិនជាប្រយោជន៍

[៣៧] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អត្ថសូត្រទី ៤

# អដ្ឋកថា ធម្មសូត្រទី ៥

*ពោលដោយធម៌ និងអធម៌*

[៣៨] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ធម្មសូត្រទី ៥

# អដ្ឋកថា អាសវធម្មសូត្រទី ៦

## *ធម៌ដែលមានអាសវៈ និងមិនមានអាសវៈ*

[៣៩] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អាសវធម្មសូត្រទី ៦

# អដ្ឋកថា សាវជ្ជសូត្រទី ៧

## *ធម៌ដែលមានទោស និងមិនមានទោស*

[៤០] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សាវជ្ជធម្មសូត្រទី ៧

# អដ្ឋកថា តបនិយធម្មសូត្រទី ៨

## *ធម៌ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ និងមិនក្ដៅក្រហាយ*

[៤១] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា តបនិយធម្មសូត្រទី ៨

# អដ្ឋកថា អាចយគាមិធម្មសូត្រទី ៩

## ធម៌ប្រព្រឹត្តទៅដើម្បីសន្សំកិលេស និងមិនសន្សំកិលេស

[៤២] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អាចយគាមិធម្មសូត្រទី ៩

# អដ្ឋកថា ទុក្ខុទ្រយធម្មសូត្រទី ១០

## *ធម៌ដែលមានទុក្ខ និងសុខជាកម្រៃ*

[៤៣] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ទុក្ខុទ្រយធម្មសូត្រទី ១០

# អដ្ឋកថា ទុក្ខវិបាកធម្មសូត្រទី ១១

## *ធម៌ដែលមានទុក្ខ និងសុខជាវិបាក*

[៤៤] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ទុក្ខវិបាកធម្មសូត្រទី ១១

## ចប់សាធុវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០១ សូត្រ

# អរិយមគ្គវគ្គវណ្ណនាទី ៥

## អដ្ឋកថា អរិយមគ្គសូត្រទី ១

*ធម៌ជាអរិយមគ្គ និងមិនមែនជាអរិយមគ្គ*

[៤៥] *អរិយមគ្គសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា អរិយមគ្គសូត្រទី ១

# អដ្ឋកថា កណ្ហមគ្គសូត្រទី ២

## *ធម៌ជាមគ្គខ្មៅ និងជាមគ្គស*

[៤៦] *កណ្ហមគ្គសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា កណ្ហមគ្គសូត្រទី ២

# អដ្ឋកថា សទ្ធម្មសូត្រទី ៣

## *ពោលដោយសទ្ធម្ម និងអសទ្ធម្ម*

[៤៧] *សទ្ធម្មសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា សទ្ធម្មសូត្រទី ៣

# អដ្ឋកថា សប្បុរិសធម្មសូត្រទី ៤

## *សប្បុរិសធម៌ និងអសប្បុរិសធម៌*

[៤៨] *សប្បុរិសធម្មសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា សប្បុរិសធម្មសូត្រទី ៤

# អដ្ឋកថា ឧប្បាទេតព្វធម្មសូត្រទី ៥

## ធម៌ដែលគួរឲ្យកើតឡើង និងធម៌មិនគួរឲ្យកើតឡើង

[៤៩] *ឧប្បាទេតព្វធម្មសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ឧប្បាទេតព្វធម្មសូត្រទី ៥

# អដ្ឋកថា អាសេវិតព្វធម្មសូត្រទី ៦

## *ធម៌ដែលគួរសេព និងមិនគួរសេព*

[៥០] *អសេវិតព្វធម្មសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អសេវិតព្វធម្មសូត្រទី ៦

# អដ្ឋកថា ភាវេតព្វធម្មសូត្រទី ៧

## *ធម៌ដែលគួរចម្រើន និងមិនគួរចម្រើន*

[៥១] *ភាវេតព្វធម្មសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ភាវេតព្វធម្មសូត្រទី ៧

# អដ្ឋកថា ពហុលីការតព្វធម្មសូត្រទី ៨

## ធម៌ដែលគួរធ្វើឲ្យច្រើន និងមិនគួរធ្វើឲ្យច្រើន

[៥២] *ពហុលីការតព្វធម្មសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ពហុលីការតព្វធម្មសូត្រទី ៨

# អដ្ឋកថា អនុស្សរិតព្វធម្មសូត្រទី ៩

## ធម៌ដែលគួររឭក និងមិនគួររឭក

[៥៣] *អនុស្សរិតព្វធម្មសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អនុស្សរិតព្វធម្មសូត្រទី ៩

# អដ្ឋកថា សច្ចិកាតព្វធម្មសូត្រទី ១០

## *ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ និងមិនគួរ*

[៥៤] *សច្ចិកាតព្វធម្មសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សច្ចិកាតព្វធម្មសូត្រទី ១០

## ចប់អរិយមគ្គវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ មិនមានព្រះអដ្ឋកថាទេ

# ចតុត្ថបណ្ណាសកៈ

## អដ្ឋកថា បុគ្គលវគ្គវណ្ណនាទី ១

### *បុគ្គលប្រកបដោយធម៌ ១០ ប្រការ*

[៥៥] *បុគ្គលវគ្គនេះ ពីសូត្រទី ១ ជាដើម មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា បុគ្គលវគ្គ សូត្រទី ១ ជាដើម

# ជាណុស្សោណិវគ្គវណ្ណនាទី ២

## អដ្ឋកថា បឋមបច្ចោរោហណិសូត្រទី ១

*វិធីបន្សាត់បាបរបស់ព្រាហ្មណ៍ និងព្រះអរិយៈ*

[៥៦] *ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា បឋមបច្ចោរោហណិសូត្រទី ១

# អដ្ឋកថា ទុតិយបច្ចោរោហណិសូត្រទី ២

## *វិធីបន្សាត់បាបរបស់ព្រះអរិយៈ*

[៥៧] *ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ទុតិយបច្ចោរោហណិសូត្រទី ២

# អដ្ឋកថា សគារវសូត្រទី ៣

## ពោលដោយត្រើយអាយ និងត្រើយនាយ

[៥៨] ក្នុងសូត្រនេះ មានអត្ថងាយហើយ ។

ចប់អដ្ឋកថា សគារវសូត្រទី ៣

# អដ្ឋកថា ឱរិមសូត្រទី ៨

*ពោលដោយត្រើយអាយ និងត្រើយនាយ*

[៥៩] *ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ឱរិមសូត្រទី ៨

# អដ្ឋកថា បឋមអធម្មសូត្រទី ៥

## ធម៌ដែលបុគ្គលគួរជ្រាប

[៦០] ក្នុងសូត្រនេះ មានអត្ថងាយហើយ ។

ចប់អដ្ឋកថា បឋមអធម្មសូត្រទី ៥

# អដ្ឋកថា ទុតិយអធម្មសូត្រទី ៦

*ធម៌ដែលបុគ្គលគួរជ្រាប*

[៦១] *ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ទុតិយអធម្មសូត្រទី ៦

# អដ្ឋកថា តតិយអធម្មសូត្រទី ៧

## *ធម៌ដែលបុគ្គលគួរជ្រាប*

*[៦២] ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា តតិយអធម្មសូត្រទី ៧

# អដ្ឋកថា តិកវិធសូត្រទី ៨

## ការអស់ហេតុរបស់កម្ម ព្រោះអស់រាគៈ ទោសៈ មោហៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុង តិកវិធសូត្រទី ៨ ដូចតទៅនេះ ៖*

[៦៣] *បទថា លោភហេតុកម្បិ (មានលោភៈជាហេតុខ្លះ) សេចក្តីថា សេចក្តីលោភជាហេតុ ដែលជាចំណែកឧបនិស្ស័យដល់បាណាតិបាត ដែលប្រកបដោយទោសៈ និងមោហៈក៏មាន ។ គប្បីជ្រាបសេចក្តីក្នុងគ្រប់បទដោយឧបាយនេះ ។*

ចប់អដ្ឋកថា តិកវិធសូត្រទី ៨

# អដ្ឋកថា សបរិក្កមនសូត្រទី ៩

## *ធម៌ដែលគួរវៀរ និងមិនគួរវៀរ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សបរិក្កមនសូត្រទី ៩ ដូចតទៅនេះ ៖*

[៦៤] *បទថា* ***បរិក្កមនំ ហោតិ*** *(ជាការវៀរចាក) បានដល់ ការវៀរចាក រមែងមាន ។*

ចប់អដ្ឋកថា បរិក្កមនសូត្រទី ៩

# អដ្ឋកថា ចុន្ទសូត្រទី ១០

## *សេចក្ដីស្អាតក្នុងវិន័យរបស់ព្រះអរិយៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចុន្ទសូត្រទី ១០ ដូចតទៅនេះ ៖*

[៦៥] *បទថា **កម្មារបុត្តស្ស** (**កម្មារបុត្ត**) ប្រែថា បុត្រជាងមាស ។ បទថា **កស្ស នោ ត្វំ** កាត់បទជា **កស្ស នុ ត្វំ** ។ បទថា **បច្ឆាភូមិកា** ប្រែថា អ្នកនៅខាងក្រោយភូមិ ។ បទថា **កមណ្ឌលុកា** ប្រែថា អ្នកកាន់ឃោក (ឃោកដែលសម្រាប់ដាក់ទឹកផឹក) ។ បទថា **សេវាលមាលកា** (ដូចកម្រងផ្កាសារាយ) បានដល់ រមែងទ្រទ្រង់ទុកដូចគ្នានឹងចំណែកកម្រងផ្កាសារាយ ។ គេពោលថា ស្លៀកសំពត់សារាយក៏មាន ។ បទថា **ឧទកោរោហកា** (ចុះត្រាំទឹក) បានដល់ ការចុះងូតទឹកព្រឹកល្ងាច ។ បទថា **អាមសេយ្យាសិ** (គប្បីចាប់ត្រូវ) បានដល់ គប្បីចាប់ត្រូវដោយដៃ ។*

ចប់អដ្ឋកថា ចុន្ទសូត្រទី ១០

# អដ្ឋកថា ជាណុស្សោណិសូត្រទី ១១

## ការឧទ្ទិសទានដល់អ្នកដែលស្លាប់ទៅហើយ

*គប្បីជ្រាបវិនិច្ឆ័យក្នុង ជាណុស្សោណិសូត្រទី ១១ ដូចតទៅនេះ ៖*

[៦៦] *បទថា* ***ឧបកប្បតុ*** *(ត្រូវសម្រេច) ប្រែថា ចូរសម្រេច ។ បទថា* ***ឋានេ*** *(ក្នុងឋានៈ) បានដល់ ក្នុងឱកាស ។ បទថា* ***នោ អដ្ឋានេ*** ***(មិន... ក្នុងអឋានៈ)*** *បានដល់ រមែងមិនសម្រេចក្នុងទីមិនមែនឱកាស ។ កម្ម ដែលឲ្យកើតក្នុងនរកនុ៎ះឯង ឈ្មោះថា អាហាររបស់ពួកសត្វនរក ព្រោះថា ពួកសត្វនរកនោះ ប្រព្រឹត្តទៅបានក្នុងនរកនោះ ក៏ដោយកម្មនោះឯង ។ ចំណែកអាហាររបស់ពួកសត្វតិរច្ឆាន ក៏គប្បីជ្រាប គឺ ស្មៅជាដើម ។ របស់ពួកមនុស្ស ក៏គឺ បាយ នំស្រស់ជាដើម ។ របស់ពួកទេវតា ក៏គឺ សុធាភោជន អាហារទិព្វជាដើម ។ របស់ពួកសត្វដែលកើតក្នុងបិត្តិវិស័យ ដែនប្រេត ក៏គឺ ទឹកមាត់ ទឹកសំបោរជាដើម ។ បទថា* ***យំ វា បនស្ស ឥតោ អនុប្បវេច្ឆន្តិ*** *(“មិត្រជាដើម” របស់គេ រមែងបន្ថែមឲ្យនូវបត្តិទានមយៈអំពីមនុស្សលោក) សេចក្តីថា ពួកមិត្តជាដើម ឲ្យ*

ទានបញ្ជូន ឧទ្ទិសផលបុណ្យណាទៅពីលោកនេះ ពួកសត្វដែលកើតក្នុងបិត្តិវិស័យដែនប្រេតប៉ុណ្ណោះ រមែងរស់នៅបានដោយផលបុណ្យនោះ ដែលបុគ្គលដទៃឧទ្ទិសទៅឲ្យ ផលបុណ្យដែលមនុស្សទាំងនោះឧទ្ទិសឲ្យ មិនបានសម្រេចដល់សត្វពួកដទៃ ។

បទថា **ទាយកោបិ អនិប្ផលោ (សូម្បីទាយកក៏ជាអ្នកមិនមែនជាគ្មានផលទេ)** សេចក្តីថា ទានដែលថ្វាយនោះ សំដៅសត្វណា នឹងសម្រេចឬមិនសម្រេចក៏ដោយ ចំណែកទាយក ក៏មិនអាចនឹងថា គ្មានផលនោះទេ ទាយករមែងបានផលនៃទាននោះដោយពិត ។ ក្នុងបទថា **អដ្ឋានេបិ ខោ គោតមោ បរិកប្បំ វទតិ (ព្រះគោតមដ៏ចម្រើន រមែងត្រាស់កំណត់សូម្បីក្នុងឋានៈឬ)** ជាណុស្សោណិព្រាហ្មណ៍ សួរថា កាលញាតិនោះ កើតឡើងក្នុងទីមិនមែនឱកាស ព្រះគោតមបញ្ញត្តិថា ផលទាននឹងសម្រេចទៀតឬ ។ ពិតហើយ ព្រាហ្មណ៍មានលទ្ធិយល់ថា ផលទានដែលឲ្យយ៉ាងនេះ ទាយកអ្នកឲ្យ រមែងមិនបាន ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបដោយព្រះបញ្ញាដល់ជាណុស្សោណិព្រាហ្មណ៍នោះ ទើបទ្រង់សម្តែងថា ធម្មតាទាយក

*កើតក្នុងទីដែលអាស្រ័យផលបុណ្យចិញ្ចឹមជីវិតកន្លែងណាមួយ រមែងបាន ផលនៃទានទាំងនោះ ទើបត្រាស់ថា ព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាដើម ។ បទថា **សោ តត្ថ លាភី ហោតិ (គេរមែងបាន... ក្នុងកំណើត ដំរីនោះ)** សេចក្តីថា ទាយកនោះ សូម្បីកើតក្នុងកំណើតដំរី កំណើតសត្តិរច្ឆាននោះ ក៏បានគ្រឿងតាំងដំរីមង្គល ។ សូម្បីក្នុងសត្វ មានសេះជាដើម ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ជាណុស្សោណិសូត្រទី ១១

## ចប់ជាណុស្សោណិវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែ ០៤ សូត្រ

# សុន្ទរវគ្គវណ្ណនាទី ៣

## អដ្ឋកថា សាធុអសាធុសូត្រទី ១

### *វត្ថុល្អ និងវត្ថុមិនល្អ*

[៦៧] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សាធុអសាធុសូត្រទី ១

# អដ្ឋកថា អរិយានរិយធម្មសូត្រទី ២

## *អរិយធម៌ និងអនរិយធម៌*

[៦៨] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អរិយានរិយធម្មសូត្រទី ២

# អដ្ឋកថា កុសលាកុសលសូត្រទី ៣

## *កុសលធម៌ និងអកុសលធម៌*

[៦៩] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា កុសលាកុសលសូត្រទី ៣

# អដ្ឋកថា អត្ថានត្ថសូត្រទី ៤

## *វត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍*

[៧០] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អត្ថានត្ថសូត្រទី ៤

# អដ្ឋកថា ធម្មាធម្មសូត្រទី ៥

## ធម៌ និងអធម៌

[៧១] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ធម្មាធម្មសូត្រទី ៥

# អដ្ឋកថា សាសវានាសវសូត្រទី ៦

## *ធម៌ដែលមានអាសវៈ និងមិនមានអាសវៈ*

[៧២] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សាសវានាសវសូត្រទី ៦

# អដ្ឋកថា សាវជ្ជានវជ្ជសូត្រទី ៧

## *ធម៌ដែលមានទោស និងមិនមានទោស*

[៧៣] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា សាវជ្ជានវជ្ជសូត្រទី ៧

# អដ្ឋកថា តបនិយាតបនិយធម្មសូត្រទី ៨

*ធម៌ជាទីតាំងសេចក្ដីក្ដៅក្រហាយ និងមិនក្ដៅក្រហាយ*

[៧៤] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា តបនិយាតបនិយធម្មសូត្រទី ៨

# អដ្ឋកថា អាចយគាមយាបចយគាមិធម្មសូត្រទី ៩

## *ធម៌ប្រព្រឹត្តទៅដើម្បីសន្សំកិលេស និងមិនសន្សំកិលេស*

[៧៥] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អាចយគាមយាបចយគាមិធម្មសូត្រទី ៩

# អដ្ឋកថា ទុក្ខុទ្រយសុខុទ្រយធម្មសូត្រទី ១០

## *ធម៌ដែលមានទុក្ខ និងសុខជាកំរៃ*

[៧៦] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ទុក្ខុទ្រយសុខុទ្រយធម្មសូត្រទី ១០

# អដ្ឋកថា ទុក្ខវិបាកសុខវិបាកធម្មសូត្រទី ១១

*ធម៌ដែលមានទុក្ខ និងសុខជាវិបាក*

[៧៧] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ទុក្ខវិបាកសុខវិបាកធម្មសូត្រទី ១១

## ចប់សុទ្ធវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១១ សូត្រ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ

# សេដ្ឋវគ្គវណ្ណនាទី ៤

## អដ្ឋកថា អរិយមគ្គានអរិយមគ្គសូត្រទី ១

### *ធម៌ដែលជាអរិយមគ្គ និងមិនមែនជាអរិយមគ្គ*

[៧៨] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា អរិយមគ្គានអរិយមគ្គសូត្រទី ១

# អដ្ឋកថា កណ្ហមគ្គសុក្កមគ្គសូត្រទី ២

*ធម៌ដែលជាមគ្គខ្មៅ និងមគ្គស*

[៧៩] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា កណ្ហមគ្គសុក្កមគ្គសូត្រទី ២

# អដ្ឋកថា សទ្ធម្មាសទ្ធម្មសូត្រទី ៣

## *ពោលដោយសទ្ធម្ម និងអសទ្ធម្ម*

[៨០] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សទ្ធម្មាសទ្ធម្មសូត្រទី ៣

# អដ្ឋកថា សប្បុរិសធម្មាសប្បុរិសធម្មសូត្រទី ៤

*ពោលដោយសប្បុរិសធម៌ និងអសប្បុរិសធម៌*

[៨១] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សប្បុរិសធម្មាសប្បុរិសធម្មសូត្រទី ៤

# អដ្ឋកថា ឧប្បាទេតព្វានុប្បាទេតព្វធម្មសូត្រទី ៥

## *ធម៌ដែលគួរឲ្យកើតឡើង និងមិនគួរឲ្យកើតឡើង*

[៨២] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ឧប្បាទេតព្វានុប្បាទេតព្វធម្មសូត្រទី ៥

# អដ្ឋកថា អាសេវិតព្វានាសេវិតព្វធម្មសូត្រទី ៦

## *ធម៌ដែលគួរសេព និងមិនគួរសេព*

[៨៣] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អាសេវិតព្វានាសេវិតព្វធម្មសូត្រទី ៦

# អដ្ឋកថា ភាវេតព្វាភាវេតព្វធម្មសូត្រទី ៧

## *ធម៌ដែលគួរឲ្យចម្រើន និងមិនគួរឲ្យចម្រើន*

[៨៤] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ភាវេតព្វាភាវេតព្វធម្មសូត្រទី ៧

# អដ្ឋកថា ពហុលីកាតព្វាពហុលីកាតព្វធម្មសូត្រទី ៨

*ធម៌ដែលគួរធ្វើឲ្យច្រើន និងមិនគួរធ្វើឲ្យច្រើន*

[៨៥] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ពហុលីកាតព្វាពហុលីកាតព្វធម្មសូត្រទី ៨

# អដ្ឋកថា អនុស្សរិតព្វានុស្សរិតព្វធម្មសូត្រទី ៩

## ធម៌ដែលគួររឭកដល់ និងមិនគួររឭកដល់

[៨៦] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អនុស្សរិតព្វានុស្សរិតព្វធម្មសូត្រទី ៩

# អដ្ឋកថា សច្ឆិកាតព្វាសច្ឆិកាតព្វធម្មសូត្រទី ១០

## *ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ និងមិនគួរ*

[៨៣] *សូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា សច្ឆិកាតព្វាសច្ឆិកាតព្វធម្មសូត្រទី ១០

## ចប់សេដ្ឋវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ

# សេវិតព្វាសេវិតព្វវគ្គវណ្ណនាទី ៥

*បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ មិនគួរគោរព*

[៨៨] *សូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សេវិតព្វាសេវិតព្វវគ្គទី ៥

## ចប់សេវិតព្វាសេវិតព្វវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះ មិនមានព្រះអដ្ឋកថាកែសេចក្តីទេ

## ចប់ចតុត្ថបណ្ណាសកៈ

# បញ្ចមបណ្ណាសកៈ

## បឋមវគ្គវណ្ណនាទី ១

## អដ្ឋកថា យថាភតសូត្រទី ១

*បុគ្គលប្រកបដោយធម៌ ១០ ប្រការ ត្រូវធ្លាក់នរក*

*និងនាំទៅតម្កល់ទុកក្នុងស្ថានសួគ៌*

[៨៩] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា យថាភតសូត្រទី ១

# អដ្ឋកថា មាតុគាមសូត្រទី ២

## មាតុគ្រាមប្រកបដោយធម៌ ១០ ប្រការ ជាអ្នកទៅកាន់

## នរក ឬឡើងស្ថានសួគ៌

[៩០] សូត្រនេះ មានសេចក្តីងាយហើយ ។

ចប់អដ្ឋកថា មាតុគាមសូត្រទី ២

# អដ្ឋកថា បឋមឧបាសិកាសូត្រទី ៣

## *ឧបាសិកាប្រកបដោយធម៌ ១០ ប្រការ ត្រូវធ្លាក់នរក និងនាំទៅតម្កល់ទុកក្នុងស្ថានសួគ៌*

[៩១] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា បឋមឧបាសិកាសូត្រទី ៣

# អដ្ឋកថា ទុតិយឧបាសិកាសូត្រទី ៤

## ឧបាសិកាប្រកបដោយធម៌ ១០ ប្រការ ជាអ្នកមិនក្លៀវក្លា និងក្លៀវក្លានៅគ្រប់គ្រងផ្ទះ

[៩១] សូត្រនេះ មានខ្លឹមសារងាយហើយ ។

ចប់អដ្ឋកថា ទុតិយឧបាសិកាសូត្រទី ៤

# អដ្ឋកថា ធម្មបរិយាយសូត្រទី ៥

## *ធម្មបរិយាយដែលជាហេតុនៃសេចក្ដីវិនាស*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មបរិយាយសូត្រទី ៥ ដូចតទៅនេះ ៖*

[៩៣] *បទថា* ***សំសប្បតិបរិយាយំ វោ ភិក្ខវេ ធម្មបរិយាយំ*** *(ម្នាលភិក្ខុទាំងឡាយ... ធម្មបរិយាយដែលជាហេតុនៃសេចក្ដីវិនាស ដល់អ្នកទាំងឡាយ) បានដល់ ការសម្ដែងធម៌ ពោលគឺ ការសម្ដែងហេតុនៃសេចក្ដីវិនាស ។ បទថា* ***សំសប្បតិ*** *(រមែងវិនាស) សេចក្ដីថា សត្វធ្វើកម្មនោះ រមែងរសាត់ទៅ ប្រាទទៅ នទៀលទៅ ។ បទថា* ***ជិម្ហា គតិ*** *(គតិ... វៀច) សេចក្ដីថា សត្វនឹងទៅកាន់គតិណាដោយកម្មនោះ គតិនោះ រមែងឈ្មោះថា វៀច ។ បទថា* ***ជិម្ហុប្បត្តិ*** *(ឧបបត្តិ... វៀច) សេចក្ដីថា សត្វនឹងចូលដល់គតិណា សូម្បីគតិរបស់គេនោះ ក៏វៀចដូចគ្នា ។ បទថា* ***សំសប្បជាតិកា*** *(ដែលមានប្រក្រតីវិនាស) បានដល់ មានការលូនទៅជាសភាព ។ បទថា* ***ភូតា ភូតស្ស ឧបបត្តិ ហោតិ*** *(ការឧប្បត្តិរបស់សត្វរមែងមានព្រោះកម្មដែលមានហើយ) សេចក្ដីថា ការកើតរបស់សត្វ រមែង*

មាន ព្រោះកម្មដែលមានហើយ គឺ ព្រោះកម្មដែលមានហើយជាសភាព ។

បទថា ផស្សា ផុសន្តិ (ផស្សៈរមែងពាល់ត្រូវ) បានដល់ ផស្សៈដែលជាវិបាក រមែងពាល់ត្រូវ ។

ចប់អដ្ឋកថា ធម្មបរិយាយសូត្រទី ៥

# អដ្ឋកថា បឋមកម្មសូត្រទី ៦

## ទីបំផុតនៃកម្ម

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមកម្មសូត្រទី ៦ ដូចតទៅនេះ ៖*

[៩៤] *បទថា* ***សញ្ចេតនិកានំ (តាំងចិត្ត)*** *បានដល់ ដែលតាំងចិត្ត កំណត់ក្នុងចិត្ត ធ្វើហើយ ។ បទថា* ***ឧបចិតានំ (សន្សំឡើង)*** *បានដល់ ដែលកសាង ឲ្យពង្រីកខ្ពស់ឡើង ។ បទថា* ***អប្បដិសំវិទិត្វា (មិនដឹង)*** *បានដល់ មិនទាន់ជ្រាបវិបាកនៃកម្មនោះ ។ បទថា* ***ព្យន្តីការំ (ទម្លាយ)*** *បានដល់ ការប្រាសចាកទីបំផុត គឺ ហេតុជុំវិញផ្លូវដែលកម្មទាំងនោះកំណត់ទុក ។ បទថា* ***តញ្ច ខោ ទិដ្ឋេវ ធម្មេ (ក៏វិបាកនោះឯង ដែលសត្វអ្នកធ្វើ បានសោយក្នុងបច្ចុប្បន្ន)*** *សេចក្ដីថា ទិដ្ឋធម្មវេទនីយកម្មរមែងឲ្យផល នោះឯងក្នុងបច្ចុប្បន្ន ។ បទថា* ***ឧបបជ្ជេ (ក្នុងអត្តភាពបន្ទាប់)*** *សេចក្ដីថា ឧបបជ្ជវេទនីយកម្ម រមែងឲ្យផលក្នុងភពបន្ទាប់ ។ បទថា* ***អបរេ វា បរិយាយេ (ឬឲ្យក្នុងអត្តភាពតៗ ទៅ)*** *សេចក្ដីថា ចំណែកអបរាបរិយវេទនីយកម្ម កាលសត្វនៅប្រព្រឹត្តទៅក្នុងសង្សារវដ្ត រមែងឲ្យផលរហូតសែន*

អត្ថកាលនោះឯង ដោយបទនេះ ទ្រង់សម្តែងសេចក្តីដូច្នេះថា ក្នុងកម្មដែលសមគួរដល់វិបាកដែលបានហើយ ក្នុងកាលសត្វនៅប្រព្រឹត្តទៅក្នុងសង្សារវដ្ត មិនមានប្រទេសនៃផែនដីដែលសត្វតាំងនៅហើយ នឹងគប្បីផុតចាកបាបកម្មទៅបាន ។ បទថា **តិវិធា** (៣ យ៉ាង) បានដល់ ៣ ប្រការ ។ បទថា **កាយកម្មន្តសន្ទោសព្យាបត្តិ** (វិបត្តិដែលជាទោសនៃការងារផ្លូវកាយ) សេចក្តីថា វិបត្តិ ពោលគឺ ទោសនៃកាយកម្ម ។ គប្បីជ្រាបក្នុងគ្រប់បទ ដោយន័យនេះ ។ បទថា **អបណ្ណកោ មណិ** (កែវមណី ៤ ជ្រុង) បានដល់ កូនអុកចត្រង្គ ។

ចប់អដ្ឋកថា បឋមកម្មសូត្រទី ៦

# អដ្ឋកថា ទុតិយកម្មសូត្រទី ៧

## *កម្មដែលសត្វតាំងចិត្តសន្សំ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយកម្មសូត្រទី ៧ ដូចតទៅនេះ ៖*

[៩៥] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា ទុតិយកម្មសូត្រទី ៧

# អដ្ឋកថា តតិយកម្មសូត្រទី ៨

## ការធ្វើទីបំផុតទុក្ខនៃកម្មដែលសត្វតាំងចិត្តធ្វើ

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយកម្មសូត្រទី ៨ ដូចតទៅនេះ ៖*

[៩៦] *បទថា **ទុក្ខស្ស (ទុក្ខ)** បានដល់ ទុក្ខដែលជាវិបាក ឬទុក្ខក្នុងវដ្ដៈ ក្នុងសូត្រនេះ មិនមានការឧបមាដោយកូនអុក ។ ពាក្យថា **ឯវំ** ក្នុងបទថា **ឯវំ វិគតាភិជ្ឈោ (ប្រាសចាកអភិជ្ឈា)** នេះ ជានិបាត ។ ន័យមួយទៀត ជនទាំងឡាយចម្រើនមេត្តា រមែងជាអ្នកប្រាសចាកអភិជ្ឈាយ៉ាងណា ព្រះអរិយសាវកក៏ជាអ្នកប្រាសចាកអភិជ្ឈាយ៉ាងនោះ ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងដល់ព្រះអរិយសាវកនោះ គួរសង្កត់នីវរណៈបាន ព្រោះជាអ្នកប្រាសចាកអភិជ្ឈាជាដើមយ៉ាងនេះហើយ កាលនឹងត្រាស់និស្សរណៈការស្ទុះចេញទៅចាកអកុសល ទើបត្រាស់ថា **មេត្តាសហគតេន** ជាដើម ។ បទថា **អប្បមាណំ (រកប្រមាណមិនបាន)** បានដល់ ឈ្មោះថាមិនមានប្រមាណ ព្រោះជាអ្នកមានសត្វមិនមានប្រមាណជាអារម្មណ៍ ឬព្រោះជាអ្នកមានភាពជំនាញដែលសន្សំហើយ ។ កាមាវចរកម្ម ឈ្មោះថា*

កម្មដែលធ្វើដោយប្រមាណ ។ បទថា **ន តំ តត្រាវ តិដ្ឋតិ (កម្ម... មិនតាំងនៅក្នុងចិត្តរបស់យើង)** សេចក្តីថា កាមាវចរកម្មនោះ មិនអាចមានឱកាសរបស់ខ្លួនតាំងនៅបាន ដូចទឹកបន្តិចបន្តួចក្នុងអន្លង់ទឹកធំ ដែលពិតកម្មដែលមិនមានប្រមាណនេះប៉ុណ្ណោះ គ្របសង្កត់កាមាវចរកម្មនោះ ដូចទឹកបន្តិចបន្តួចក្នុងអន្លង់ទឹក រមែងធ្វើវិបាករបស់ខ្លួនឲ្យកើត ។

បទថា **ទហរតគ្គេ (ក្នុងវេលានៅក្មេង)** បានដល់ តាំងពីវេលានៅក្មេង ។ បទថា **នាយំ កាយោ អាទាយ គមនីយោ (កាយនេះមិនបានមានចំណែក... នឹងគប្បីយកទៅបាន)** សេចក្តីថា មិនអាចនាំកាយនេះទៅកាន់បរលោកបាន ។ បទថា **ចិត្តន្តរោ** ប្រែថា មានចិត្តជាហេតុ ។ ន័យមួយទៀត សេចក្តីថា ប្រព្រឹត្តទៅក្នុងលំដាប់ ដោយចិត្តនោះឯង ។ អធិប្បាយថា ពិតណាស់ ដែលឈ្មោះថា ទេវៈ ឈ្មោះថា សត្វនរក ឈ្មោះថា សត្វតិរច្ឆាន ក៏ព្រោះបដិសន្ធិចិត្តជួងទី ២ ក្នុងលំដាប់នៃចុតិចិត្តជួងទី ១ នុ៎ះឯង ។ តែក្នុងន័យខាងដើម នឹងជាទេវៈ ឬសត្វនរក ក៏ព្រោះចិត្តដែលជាតួហេតុ ។ បទថា **សព្វន្តំ ឥធ វេទនីយំ (បាបកម្មទាំងអស់នោះ ដែល**

*យើងគប្បីសោយក្នុងអត្តភាពនេះ)* នេះ ត្រាស់ដោយអំណាចចំណែកនៃទិដ្ឋធម្មវេទនីយកម្ម ។ បទថា **ន តំ អនុកវិស្សតិ** *(នឹងជាប់តាមទៅ)* សេចក្តីថា នឹងជាកម្មដែលមិនប្រព្រឹត្តតាមទៅ ដោយអំណាចឧបបជ្ជវេទ-នីយកម្ម ព្រោះជាឧបបជ្ជវេទនីយកម្ម ត្រូវមេត្តាកាត់ផ្តាច់ហើយ ។ តែសេចក្តីនេះគប្បីជ្រាបថា ជាបច្ចវេក្ខណញ្ញាណរបស់ព្រះអរិយបុគ្គល គឺព្រះសោតាបន្ន និងព្រះសកទាគាមី ។ បទថា **អនាគាមិតាយ** *(ដើម្បីជាព្រះអនាគាមី)* បានដល់ ដើម្បីជាព្រះអនាគាមីដោយញាណ ។ បទថា **ឥធ បញ្ញស្ស** *(អ្នកមានបញ្ញា...ក្នុងធម្មវិន័យនេះ)* សេចក្តីថា ឈ្មោះថាបញ្ញាក្នុងព្រះសាសនានេះ ជារបស់សម្រាប់ព្រះអរិយសាវកដែលតាំងនៅក្នុងអរិយបញ្ញា ដែលជាសាសនចារិត ។ បទថា **អនុត្តរី វិមុត្តី** *(វិមុត្តិដ៏ប្រសើរ)* បានដល់ ព្រះអរហត្ត ។

ចប់អដ្ឋកថា តតិយកម្មសូត្រទី ៩

# អដ្ឋកថា ព្រាហ្មណសូត្រទី ៩

## *ហេតុបច្ច័យដែលឲ្យសត្វចូលដល់*

## *អបាយ ទុគ្គតិ វិនិបាត នរក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រាហ្មណសូត្រទី ៩ ដូចតទៅនេះ ៖*

[៩៧] *ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ព្រាហ្មណសូត្រទី ៩

**ចប់បឋមវគ្គវណ្ណនាទី ១**

ក្នុងវគ្គនេះមាន ៩ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៣ សូត្រ

# ទុតិយវគ្គវណ្ណនាទី ២

## អដ្ឋកថា សូត្រទី ១

*បុគ្គលប្រកបដោយធម៌ ១០ ប្រការ*

[៩៨] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថា សូត្រទី ២

## *បុគ្គលប្រកបដោយធម៌ ២០ ប្រការ*

[៩៩] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថា សូត្រទី ៣

## *បុគ្គលប្រកបដោយធម៌ ៣០ ប្រការ*

[១០០] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថា សូត្រទី ៤

## *បុគ្គលប្រកបដោយធម៌ ៤០ ប្រការ*

[១០១] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថា សូត្រទី ៥

## បុគ្គលប្រកបដោយធម៌ ១០ ប្រការ

[១០២] សូត្រនេះ មានខ្លឹមសារងាយហើយ ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថា សូត្រទី ៦

*បុគ្គលប្រកបដោយធម៌ ២០ ប្រការ*

[១០២] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថា សូត្រទី ៧

## បុគ្គលប្រកបដោយធម៌ ៣០ ប្រការ

[១០២] សូត្រនេះ មានខ្លឹមសារងាយហើយ ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថា សូត្រទី ៨

## *បុគ្គលប្រកបដោយធម៌ ៤០ ប្រការ*

[១០២] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៨

## ចប់ទុតិយវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ៨ សូត្រ មិនមានព្រះអដ្ឋកថាកែអត្ថទេ

# តតិយវគ្គវណ្ណនាទី ៣

## អដ្ឋកថា សូត្រទី ១

*បុគ្គលប្រកបដោយធម៌ ១០ ប្រការ*

[១០៣] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថា សូត្រទី ២

## *បុគ្គលប្រកបដោយធម៌ ២០ ប្រការ*

[១០៣] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថា សូត្រទី ៣

## បុគ្គលប្រកបដោយធម៌ ៣០ ប្រការ

## ស្លាប់ហើយទៅកាន់អបាយ ឬសុគតិ

[១០៣] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថា សូត្រទី ៤

## *បុគ្គលប្រកបដោយធម៌ ៤០ ប្រការ*

## *ស្លាប់ហើយទៅកាន់អបាយ ឬសុគតិ*

[១០៣] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថា សូត្រទី ៥

## បុគ្គលប្រកបដោយធម៌ ១០ ប្រការ

## ជាពាល និងបណ្ឌិត

[១០៣] សូត្រនេះ មានខ្លឹមសារងាយហើយ ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថា សូត្រទី ៦

## *បុគ្គលប្រកបដោយធម៌ ២០ ប្រការ*

## *ជាពាល និងបណ្ឌិត*

[១០៣] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថា សូត្រទី ៧

## បុគ្គលប្រកបដោយធម៌ ៣០ ប្រការ

## ជាពាល និងបណ្ឌិត

[១០៣] សូត្រនេះ មានខ្លឹមសារងាយហើយ ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថា សូត្រទី ៨

## *បុគ្គលប្រកបដោយធម៌ ៤០ ប្រការ*

## *ជាពាល និងបណ្ឌិត*

[១០៣] *សូត្រនេះ មានខ្លឹមសារងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ៨

*គប្បីជ្រាបការរាប់ចំនួនព្រះសូត្រក្នុងវគ្គទី ៤ ទី ៥*

*ដោយចំនួនបេយ្យាល*

[១០៤-១០៥-១០៦-១០៧-] *សេចក្តីមានក្នុងបិដកហើយ ។*

ចប់អដ្ឋកថា សូត្រទី ៩

## ចប់តតិយវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះ មិនមានព្រះអដ្ឋកថាកែសេចក្តីទេ

**ចប់បញ្ចមបណ្ណាសកៈ**

# ចប់ទសកនិបាត

# ឯកាទសកនិបាត

# និស្សយវគ្គវណ្ណនាទី ១

## អដ្ឋកថា កិមត្ថិយសូត្រទី ១

### *ផលរបស់សីលដែលជាកុសល*

[១០៨] *ព្រះអដ្ឋកថាកែសេចក្ដីរម ខាងចុងសូត្រទី ៥ ។*

ចប់អដ្ឋកថា កិមត្ថិយសូត្រទី ១

# អដ្ឋកថា ចេតនាសូត្រទី ២

## *អានិសង្សរបស់អ្នកមានសីល*

[១០៩] *ព្រះអដ្ឋកថាកែសេចក្ដីរួម ខាងចុងសូត្រទី ៥ ។*

ចប់អដ្ឋកថា ចេតនាសូត្រទី ២

# អដ្ឋកថា បឋមឧបនិស្សាសូត្រទី ៣

*អវិប្បដិសារ មានហេតុដែលបុគ្គល*

*ទុស្សីល មានសីលវិបត្តិកម្ចាត់ចេញហើយ*

[១១០] *ព្រះអដ្ឋកថាកែសេចក្តីរួម ខាងចុងសូត្រទី ៥ ។*

ចប់អដ្ឋកថា បឋមឧបនិស្សាសូត្រទី ៣

# អដ្ឋកថា ទុតិយឧបនិស្សាសូត្រទី ៤

## *បុគ្គលទ្រុស្តសីល កម្ចាត់អវិប្បដិសារៈ*

[១១១] *ព្រះអដ្ឋកថាកែសេចក្ដីរួម ខាងចុងសូត្រទី ៥ ។*

ចប់អដ្ឋកថា ទុតិយឧបនិស្សាសូត្រទី ៤

# អដ្ឋកថា តតិយឧបនិស្សាសូត្រទី ៥

## *បុគ្គលទ្រុស្តសីល កម្ចាត់អវិប្បដិសារៈ*

[១១២] *ព្រះអដ្ឋកថាកែសេចក្តីរួម ខាងចុងសូត្រទី ៥ ។*

ចប់អដ្ឋកថា តតិយឧបនិស្សាសូត្រទី ៥

# អដ្ឋកថា តែសូត្រនោះ ៥

*កិមត្ថិយសូត្រទី ១ ពីលេខឃ្នាប [១០៨] ជាដើម នៃឯកាទសកនិបាត មានន័យដូចពោលទុកហើយក្នុងខាងក្រោយ ។ ឯក្នុងឯកាទសកនិបាត ៥ សូត្រ ខាងដើម លោកពោលអង្គ ១១ ចែកនិព្វាន និងវិភាគៈ ចេញជាពីរ ។*

ចប់អដ្ឋកថា កិមត្ថិយសូត្រជាដើម

# អដ្ឋកថា ព្យសនសូត្រទី ៦

## *សេចក្តីវិនាស ១១ យ៉ាង*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្យសនសូត្រទី ៦ ដូចតទៅនេះ ៖*

[១១៣] *ការប្រាប់លាសិក្ខា គប្បីជ្រាបថា ហួស ។*

ចប់អដ្ឋកថា ព្យសនសូត្រទី ៦

# អដ្ឋកថា សញ្ញាសូត្រទី ៧

## បុគ្គលមានសញ្ញាក្នុងអារម្មណ៍ផ្សេងៗ គ្នា

*គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញាសូត្រទី ៧ ដូចតទៅនេះ ៖*

[១១៤] *រូបារម្មណ៍ ដែលចក្ខុវិញ្ញាណឃើញហើយជាដើម ។ បទថា* **អត្ថេន អត្ថោ** *ប្រែថា អត្ថនឹងអត្ថ ។ បទថា* **ព្យញ្ជនេន ព្យញ្ជនំ** *ប្រែថា ព្យញ្ជនៈនឹងព្យញ្ជនៈ ។ បទថា* **សំសន្ទិស្សតិ** *(ប្រៀបធៀបគ្នាបាន) បានដល់ នឹងប្រព្រឹត្តទៅជាមួយគ្នាបាន ។ បទថា* **សមេស្សតិ** *(ស្មើគ្នា) បានដល់ នឹងស្មើគ្នាបាន ។ បទថា* **ន វិគ្គយ្ហិស្សតិ** *ប្រែថា មិនខុសគ្នា ។ បទថា* **អគ្គបទស្មឹ** *(ក្នុងបទដ៏ប្រសើរ) បានដល់ ក្នុងព្រះនិព្វាន ។*

ចប់អដ្ឋកថា សញ្ញាសូត្រទី ៧

# អដ្ឋកថា មនសិការសូត្រទី ៨

## *ការធ្វើអារម្មណ៍ផ្សេងៗ ទុកក្នុងចិត្ត*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មនសិការសូត្រទី ៨ ដូចតទៅនេះ ៖*

[១១៥] *ព្រះមានព្រះភាគ ទ្រង់ត្រាស់ដល់បច្ចវេក្ខណញ្ញាណ ។*

ចប់អដ្ឋកថា មនសិការសូត្រទី ៨

# អដ្ឋកថា អសេក្ខសូត្រទី ៩

## *ការគិតរបស់សេះអាជានេយ្យ និងសេះខូក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសេក្ខសូត្រទី ៩ ដូចតទៅនេះ ៖*

[១១៦] *បទថា* ***ទោណិយា ពន្ធោ*** *(ត្រូវគេចងទុកជិតក្រង់ស្មៅ) សេចក្តីថា សេះខូកដែលគេចងទុកជិតក្រង់ស្មៅដំណើប ។ បទថា* ***អន្តរំ ករិត្វា*** *(ធ្វើ... ក្នុងខាងក្នុងហើយ) សេចក្តីថា ធ្វើ (ភគៈ) ទុកក្នុងខាងក្នុង ។ បទថា* ***ឈាយតិ*** *(រមែងសម្លឹង) សេចក្តីថា រមែងគិត ។ បទថា* ***បជ្ឈាយតិ*** *(រមែងសម្លឹងទៅផ្សេងៗ) សេចក្តីថា រមែងសម្លឹងឈាន មានប្រការផ្សេងៗ ខាងនេះខ្លះខាងនោះខ្លះ ។ បទថា* ***និជ្ឈាយតិ*** *(រមែងសម្លឹងរឿយៗ) សេចក្តីថា រមែងសម្លឹងឈានរឿយៗ ដោយមិនមានចន្លោះ ។ បទថា* ***បឋវិម្បិ និស្សាយ ឈាយតិ*** *(រមែងសម្លឹងអាស្រ័យបឋវីធាតុខ្លះ) នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចបុគ្គល ដែលនៅត្រេកអរក្នុងសមាបត្តិ ។ ព្រោះថា បឋវីធាតុនេះ ឈ្មោះថា ជាចំណែកតិចតួចដែលបុគ្គលបានធ្វើហើយ ព្រោះខ្លួននៅត្រេកអរនៅក្នុងសមាបត្តិ សូម្បីក្នុង*

អាបោធាតុជាដើម ក៏ន័យនេះដូចគ្នា ។

បទថា កថញ្ច សន្ធ អាជានីយឈាយតិ ហោតិ (សន្ធៈ ក៏ការគិតរបស់សេះអាជានេយ្យរមែងមានយ៉ាងណា) សេចក្តីថា សេះសិន្ធព រមែងដឹងហេតុដែលសមគួរ និងមិនសមគួរ គិតយ៉ាងណា ។ ក្នុងបទជាអាទិ៍ថា យថាឥណំ (ដូចបុគ្គលជំពាក់បំណុល រមែងគិតដល់បំណុល) គប្បីជ្រាបអធិប្បាយថា សេះអាជានេយ្យ រមែងសម្លឹងឃើញការពាល់ត្រូវ ពោលគឺ ការវាយដោយរំពាត់ចំពោះមុខ ធ្វើឲ្យដូចជាបំណុល ដូចជាចំណង ដូចជាសេចក្តីសាបសូន្យ ដូចជាកំហុស ពោលគឺ ទោស ។

បទថា នេវ បឋវឹ និស្សាយ ឈាយតិ (រមែងមិនគិត ព្រោះអាស្រ័យបឋវី) សេចក្តីថា បុរសអាជានេយ្យនោះ រមែងមិនសម្លឹងដោយសញ្ញាក្នុងឈានដែលប្រកបដោយអង្គ ៤ និងអង្គ ៥ ដែលមានបឋវីធាតុជាអារម្មណ៍ ព្រោះមិនត្រេកអរចំពោះសុខក្នុងសមាបត្តិ រមែងសម្លឹងអារម្មណ៍ដែលប្រាកដច្បាស់ បុរសនេះឈ្មោះថា បុរសអាជានេយ្យ ព្រោះមិនមានសេចក្តីត្រេកអរ ។ រមែងសម្លឹងដោយផលសមាបត្តិ ដែលមានព្រះនិព្វាន

ជាអារម្មណ៍ ។ បទថា **បឋវិយំ បឋវីសញ្ញា វិភូតា ហោតិ (សម្គាល់ក្នុងបឋវីធាតុថាជាបឋវីធាតុ ជាប្រាកដ)** សេចក្តីថា សេចក្តីសម្គាល់ក្នុងឈានមានអង្គ ៤ ឬឈានមានអង្គ ៥ ព្រោះមានបឋវីធាតុជាអារម្មណ៍កើតឡើងហើយ រមែងជាធម្មជាតិប្រាកដច្បាស់ គឺ ប្រាកដហើយ ។ ក៏ក្នុងព្រះសូត្រនេះ មានជាអាទិ៍ថា "បពិត្រព្រះអង្គដ៏ចម្រើន រូបសញ្ញាប្រាកដ អដ្ឋិកសញ្ញាមិនប្រាកដ" គឺ ព្រះសន្ទះពោលដល់បឋវីធាតុប្រាកដច្បាស់ ព្រោះនៅមានការឈានកន្លង ។ ក៏ក្នុងព្រះសូត្រនេះ រូបសញ្ញានោះ ឈ្មោះថា ប្រាកដច្បាស់ ព្រោះជាធម្មជាតិដែលឃើញបានថា ជារបស់មិនទៀង ជាទុក្ខ និងជាអនត្តា ដោយអំណាចនៃវិបស្សនា ។ សូម្បីក្នុងអាបោសញ្ញាជាដើម ក៏ន័យនេះដូចគ្នា ។ ក្នុងព្រះសូត្រនេះ មិនត្រាស់ការឈានកន្លងដោយអំណាចសមាបត្តិ តែត្រាស់ការឈានកន្លង ដោយអំណាចវិបស្សនាវារៈដូចក្នុងខាងក្រោយ ដោយប្រការដូច្នេះ ។ បទថា **ឯវំ ឈាយី (បុគ្គលគិតយ៉ាងនេះ)** សេចក្តីថា បុរសអាជានេយ្យសម្ងំដោយផលសមាបត្តិដែលកើតមកតាមលំដាប់នៃវិបស្សនាយ៉ាងនេះ ។

ចប់អដ្ឋកថា អសេក្ខសូត្រទី ៩

# អដ្ឋកថា មោរនិវាបនសូត្រទី ១០

## *បុគ្គលប្រកបដោយធម៌ ៣ ប្រការ*

## *ជាអ្នកមានសេចក្ដីសម្រេចដ៏សម្បូរ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មោរនិវាបនសូត្រទី ១០ ដូចតទៅនេះ ៖*

[១១៧] *បទថា* ***អច្ចន្តនិដ្ឋោ*** *គប្បីជ្រាប បទវិគ្រោះថា ព្រះនិព្វាន ពោលគឺ សេចក្ដីសម្បូរ ព្រោះកន្លងទីបំផុតហើយ មានសេចក្ដីមិនវិនាស ជាធម៌ គឺ សេចក្ដីសម្រេច របស់ភិក្ខុណា ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា* ***អច្ចន្តនិដ្ឋោ*** *អ្នកមានសេចក្ដីសម្រេចដែលបរិបូរណ៍ ។ បទដ៏សេសគប្បីជ្រាបដោយន័យនេះ ។*

*បទថា* ***ជនេតស្មឹ*** *ប្រែថា ក្នុងពពួកជន អធិប្បាយថា ក្នុងពួកសត្វ ។ បទថា* ***យេ គោត្តប្បដិសារិនោ*** *(ជាអ្នកប្រកាន់ដោយគោត្រ) សេចក្ដីថា ជនពួកណា រមែងប្រកាន់ក្នុងត្រកូលនោះថា "យើងជាត្រកូលគោតមៈ យើងជាត្រកូលកស្សបៈ" ក្នុងបណ្ដាការប្រកាន់ដោយត្រកូលទាំងនោះ ត្រកូលក្សត្រិយ៍ប្រសើរបំផុតក្នុងលោក ។ បទថា* ***អនុមតា មយា*** *(យើងឃើញ)*

សេចក្ដីថា គាថាដែលសនន្កុមារព្រហ្មសម្ដែង ប្រៀបបានទឹងសព្វញ្ញុតញ្ញាណ របស់តថាគត តថាគតក៏អនុញ្ញាត ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយហើយ ។

ចប់អដ្ឋកថា មោរនិវាបនសូត្រទី ១០

## ចប់និស្សាយវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែសេចក្ដី ០៦ សូត្រ

# ទុតិយវគ្គវណ្ណនាទី ២

## អដ្ឋកថា បឋមមហានាមសូត្រទី ១

### *សក្យមហានាមទូលសួរដល់ធម៌ជាគ្រឿងនៅ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមហានាមសូត្រទី ១ ដូចតទៅនេះ ៖*

[១១៨] *បទថា* **នានាវិហារេហិ វិហរតំ** *(អ្នកនៅដោយធម៌ជាគ្រឿងនៅផ្សេងៗ) សេចក្តីថា ឈ្មោះថា ធម៌ជាគ្រឿងនៅប្រចាំសម្រាប់គ្រហស្ថ មិនមែនមានតែម្យ៉ាង ព្រោះហេតុនោះ សក្យមហានាមទើបទូលសួរថា កាលខ្ញុំព្រះអង្គនៅដោយធម៌ជាគ្រឿងនៅមិនប្រចាំ ។ ដោយបទថា* **កេន វិហារេន** *(ដោយធម៌ជាគ្រឿងនៅ ដូចម្តេច) សក្យមហានាមទូលសួរថា ខ្ញុំព្រះអង្គគប្បីនៅដោយធម៌ជាគ្រឿងជាប្រចាំដូចម្តេច ព្រះអង្គ ។ បទថា* **អារាធកោ** *(ជាអ្នកបរិបូរណ៍) បានដល់ អ្នកធ្វើឲ្យដល់ព្រម គឺអ្នកបរិបូរណ៍ ។ បទថា* **ធម្មសោតសមាបន្នោ ពុទ្ធានុស្សតឹ ភាវេតិ** *ប្រែថា អ្នកដល់ព្រមដោយក្រសែធម៌ហើយ រមែងចម្រើនពុទ្ធានុស្សតិ ។*

ចប់អដ្ឋកថា បឋមមហានាមសូត្រទី ១

# អដ្ឋកថា ទុតិយមហានាមសូត្រទី ២

## សក្យមហានាមទូលសួរដល់ធម៌ជាគ្រឿងនៅ

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយមហានាមសូត្រទី ២ ដូចតទៅនេះ ៖*

[១១៩] *បទថា គិលានា វុដ្ឋិតោ (ទ្រង់វិនាសចាកប្រឈួន) សេចក្តីថា សក្យមហានាមទ្រង់សះស្បើយចាកជំងឺ មិនទាន់យូរប៉ុន្មាន ។*

ចប់អដ្ឋកថា ទុតិយមហានាមសូត្រទី ២

# អដ្ឋកថា នន្ទិយសូត្រទី ៣

## *នន្ទិយសក្យៈ ទូលសួរដល់ធម៌ជាគ្រឿងនៅ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នន្ទិយសូត្រទី ៣ ដូចតទៅនេះ ៖*

[១២០] *បទថា **កល្យាណមិត្តេ** (**កល្យាណមិត្ត**) ប្រែថា មិត្តល្អទាំងឡាយ ។ ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគ ត្រាស់សង្ឃានុស្សតិដោយអំណាចនៃកល្យាណមិត្ត ដោយប្រការដូច្នេះ ។ បទថា **កវឡីង្ការ-ភក្ខានំ** (**នៃទេវតាដែលមានដុំបាយជាអាហារ**) បានដល់ របស់ទេវតាជាន់កាមាវចរៈ ។ បទថា **អសមយវិមុត្តោ** (**បុគ្គលជាអសមយវិមុត្តិ**) សេចក្ដីថា ព្រះខីណាស្រពដែលរួចផុតហើយ ដោយអសមយវិមុត្តិ ។*

ចប់អដ្ឋកថា នន្ទិយសូត្រទី ៣

# អដ្ឋកថា សុក្កូតិសូត្រទី ៤

## *លក្ខណៈរបស់សទ្ធា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុក្កូតិសូត្រទី ៤ ដូចតទៅនេះ ៖*

[១២១] *ព្រះសាស្តាសូម្បីទ្រង់ជ្រាបហើយ ក៏ត្រាស់សួរថា ម្នាលសុក្កូតិ ភិក្ខុនេះឈ្មោះអ្វី ដូច្នេះ ព្រះសុក្កូតិក្រាបទូលថា ភិក្ខុនេះឈ្មោះថាសទ្ធៈ ជាបុត្ររបស់ឧបាសកអ្នកមានសទ្ធា សំដៅដល់អនាថបិណ្ឌិកគហបតី ព្រោះថា សទ្ធភិក្ខុនោះ ជាបុត្ររបស់អនាថបិណ្ឌិកគហបតី បួសក្នុងសម្នាក់ (ព្រះសុក្កូតិ) ដែលជាពូរបស់ខ្លួន ។ លំដាប់នោះ ព្រះសុក្កូតិត្ថេរ បាននាំសទ្ធភិក្ខុទៅគាល់ព្រះសាស្តា ។ បទថា* ***សទ្ធាបទានេសុ (ក្នុងលក្ខណៈរបស់អ្នកមានសទ្ធា)*** *សេចក្តីថា ក្នុងអបទាន គឺ លក្ខណៈរបស់បុគ្គលដែលមានសទ្ធាទាំងឡាយ ។*

ចប់អដ្ឋកថា សុក្កូតិសូត្រទី ៤

# អដ្ឋកថា មេត្តាសូត្រទី ៥

## *អានិសង្សរបស់មេត្តា ១១ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មេត្តាសូត្រទី ៥ ដូចតទៅនេះ ៖*

[១២២] *បទថា **សុខំ សុបតិ (រមែងលក់ជាសុខ)** សេចក្តីថា ឈ្មោះថា លក់ជាសុខ ព្រោះមិនលក់ដូចមនុស្សក្រៅពីនោះ ដែលដេករសាប់រសល់លក់ជាទុក្ខ សូម្បីកាលចុះកាន់សេចក្តីលក់ក៏ជាសុខ ដូចអ្នកចូលសមាបត្តិ ។*

*បទថា **សុខំ បដិពុជ្ឈតិ (រមែងភ្ញាក់ជាសុខ)** សេចក្តីថា មនុស្សដទៃៗ ដកដង្ហើម ក៏រសាប់រសល់ ភ្ញាក់ជាទុក្ខយ៉ាងណា បុគ្គលដែលសេពមេត្តាចេតោវិមុត្តិ ភ្ញាក់ជាទុក្ខមិនមាន មិនមានអាការខុសប្រក្រតី ភ្ញាក់ជាសុខ ដូចផ្កាបទុមកំពុងរីក ។*

*បទថា **ន បាបកំ សុបិនំ បស្សតិ (មិនឃើញនូវសុបិនអាក្រក់)** សេចក្តីថា បុគ្គលដែលសេពមេត្តាចេតោវិមុត្តិ សូម្បីកាលយល់សប្តិឃើញ ក៏យល់សប្តិឃើញតែរឿងដែលចម្រើនប៉ុណ្ណោះ ដូចជាថ្វាយបង្គំព្រះចេតិយ*

ធ្វើការបូជា ស្តាប់ធម៌ ដូច្នោះ និងរមែងមិនយល់សប្តិឃើញអាក្រក់ ដូចបុគ្គលពួកដទៃ ដែលយល់សប្តិឃើញខ្លួនត្រូវពួកចោរនាំគ្នាលោមព័ទ្ធ ដូចត្រូវសត្វកាចប្រទូសរាយ និងដូចជាកំពុងធ្លាក់ជ្រោះ ដូច្នោះ ។

បទថា ***មនុស្សានំ បិយោ ហោតិ*** (រមែងជាទីស្រឡាញ់របស់មនុស្សទាំងឡាយ) សេចក្តីថា បុគ្គលដែលសេពមេត្តាចេតោវិមុត្តិ រមែងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មនុស្សទាំងឡាយ ដូចកែវមុក្តាដែលពាក់ត្រង់ក និងដូចកម្រងផ្កាប្រដាប់ទុកត្រង់សិសៈ ដូច្នោះ ។

បទថា ***អមនុស្សានំ បិយោ ហោតិ*** (រមែងជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ) សេចក្តីថា បុគ្គលដែលសេពមេត្តាចេតោវិមុត្តិ រមែងជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ ដូចជាទីស្រឡាញ់របស់មនុស្សទាំងឡាយ ដូចព្រះវិសាខត្ថេរៈ ។ រឿងពោលទុកពិស្តារហើយ ក្នុងមេត្តាកម្មដ្ឋាននិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនុ៎ះឯង ។

បទថា ***ទេវតា រក្ខន្តិ*** (ទេវតារមែងរក្សា) សេចក្តីថា ទេវតាទាំងឡាយរមែងរក្សា ដូចមាតា និងបិតារក្សាបុត្រ ដូច្នោះ ។

បទថា នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ (ភ្លើងក្តី ថ្នាំពិសក្តី ឬសស្ត្រាក្តី រមែងមិនចូលដល់កាយបាន) សេចក្តីថា ភ្លើងក្តី រមែងមិនចូលដល់ គឺ មិនចូលទៅបៀតបៀនរាងកាយរបស់បុគ្គលនៅដោយមេត្តា ដូចនាងឧត្តរាឧបាសិកា ថ្នាំពិសក្តី រមែងមិនចូលដល់ គឺ មិនចូលទៅធ្វើអន្តរាយរាងកាយរបស់បុគ្គលនៅដោយមេត្តា ដូចជាព្រះចូឡសីវថេរៈ អ្នកសូត្រសំយុត្តនិកាយ ដូច្នោះ ឬសស្ត្រាក្តី រមែងមិនចូលដល់ គឺ រមែងមិនចូលជិតរាងកាយរបស់អ្នកនៅដោយមេត្តា ដូចជាព្រះសង្កិច្ចសាមណេរ ដូច្នោះ មានពាក្យអធិប្បាយថា ភ្លើងក្តី ថ្នាំពិសក្តី សស្ត្រាក្តី រមែងមិនធ្វើអន្តរាយរាងកាយរបស់អ្នកនៅដោយមេត្តា ក៏ក្នុងសេចក្តីនេះ លោកអាចារ្យទាំងឡាយ បានពោលរឿងមេគោទុកដូច្នេះ ។

បានឮថា មេគោមួយក្បាល កំពុងឈរបំបៅដោះដល់កូនគោ នាយព្រានម្នាក់គិតថា យើងនឹងចាក់មេគោនោះ ទើបប្រើដៃគ្រវាសលំពែងទៅមកបោះលំពែងដ៏វែងទៅ លំពែងនោះឯងក៏សុះទៅប៉ះខ្ទប់ខ្ទនមេគោនោះ ដូចជាស្លឹកត្នោតហើយទៅប៉ះ ដូច្នោះ ព្រោះកំពុងឧបចារភាវនាក៏មិនមែន ព្រោះកំពុង

អប្បនាការនោក៏មិនមែន តែព្រោះមេគោនោះ មានចិត្តអនុគ្រោះយ៉ាងខ្លាំង ក្នុងកូនគោតែម្យ៉ាង ។ មេត្តាមានអានុភាពច្រើនយ៉ាងនេះ ។

បទថា *តុវដ្ដំ ចិត្តំ សមាធិយតិ (ចិត្តរមែងតាំងមាំដោយរហ័ស)* សេចក្ដីថា ចិត្តរបស់បុគ្គលដែលនៅដោយមេត្តា រមែងតាំងមាំបានរហ័ស សភាពនៃចិត្តនោះតាំងមាំយឺតយូរ មិនមាន ។

បទថា *មុខវណ្ណោ វិប្បសីទតិ (សម្បុរមុខរមែងផូរផង់)* សេចក្ដីថា សម្បុរមុខរបស់បុគ្គលនោះរមែងថ្លាផូរផង់ ដូចផ្លែត្នោតទុំជ្រុះចាកទងដូច្នោះ ។

បទថា *អសម្មូឡ្ហោ កាលំ ករោតិ (ជាអ្នកមិនវង្វេងក្នុងពេលស្លាប់)* សេចក្ដីថា ឈ្មោះថា សេចក្ដីវង្វេងក្នុងពេលស្លាប់របស់បុគ្គលនៅដោយមេត្តា មិនមាន ។ រមែងមិនវង្វេងក្នុងកាលជិតស្លាប់ ដូចគ្មានឹងការចុះកាន់សេចក្ដីលក់ ។

បទថា *ឧត្តរឹ អប្បដិវិជ្ឈន្តោ (បើមិនទាន់ចាក់ធ្លុះគុណដ៏ក្រៃលែង)* សេចក្ដីថា បុគ្គលដែលនៅដោយមេត្តា កាលមិនទាន់សម្រេចព្រះអរហត្ត

*ដែលជាគុណវិសេសដ៏ក្រៃលែងជាងមេត្តាសមាបត្តិ ចុតិចាកអត្តភាពនោះ ហើយ ទៅកើតក្នុងព្រហ្មលោក ដូចដេកលក់ហើយភ្ញាក់ឡើង ។*

ចប់អដ្ឋកថា មេត្តាសូត្រទី ៥

# អដ្ឋកថា ទសមសូត្រទី ៦

## ធម៌ឯកដែលជាទីរួបផុតនៃចិត្ត ដែលមិនទាន់រួបផុត

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទសមសូត្រទី ៦ ដូចតទៅនេះ ៖*

[១២៣] *បទថា **ទសមោ (ទសមៈ)** សេចក្ដីថា ក៏គហបតីនោះគេរាប់ក្នុងតំណែងទី ១០ ដោយអំណាចជាតិ និងត្រកូល និងដោយការរាប់ត្រកូលដែលជាគហបតីមហាសាល ព្រោះហេតុនោះ គេទើបឈ្មោះថា ទសមៈ ទុះឯង ។ បទថា **អដ្ឋកនាគរោ** ប្រែថា អ្នកក្រុងអដ្ឋកៈ ។ បទថា **កុក្កុដារាមេ (កុក្កុដារាម)** បានដល់ អារាមដែលកុក្កុដសេដ្ឋីកសាង ។*

*ក្នុងបទថា **តេន ភគវតា ។បេ។ សម្មទក្ខាតោ** (ព្រះមានព្រះភាគព្រះអង្គនោះ ។ល។ ត្រាស់ទុកដោយល្អ) នេះ មានសេចក្ដីសង្ខេបដូចតទៅនេះ ។ ទសមគហបតី សួរព្រះអានន្ទថា ព្រះដ៏មានព្រះភាគទ្រង់បំពេញព្រះបារមី ៣០ ហើយ ទ្រង់កាច់បំបាក់កិលេសទាំងពួង ទ្រង់ដឹងក្រៃលែងនូវអនុត្តរសម្មាសម្ពោធិញ្ញាណនោះ ដែលទេវតា និងមនុស្សទាំងឡាយសរសើរដោយហេតុ ៤ ប្រការ ដោយអំណាចនៃវេសារជ្ជញ្ញាណ ៤*

យ៉ាង គឺ ព្រះអង្គទ្រង់ដឹងអជ្ឈាស្រ័យ និងអនុស័យរបស់សត្វទាំងឡាយ នោះៗ ទ្រង់ឃើញញេយ្យធម៌ទាំងពួង ដូចជាផ្លែកន្ទួតព្រៃដាក់លើបាតដៃ មួយទៀត ទ្រង់ដឹងដោយបុព្វេនិវាសញ្ញាណជាដើម ទ្រង់ឃើញដោយទិព្វចក្ខុ ឬថា ទ្រង់ដឹងដោយវិជ្ជា ៣ ឬដោយដោយអភិញ្ញា ៦ ដែលអាចដឹងធម៌ ទាំងពួង ឬទ្រង់ឃើញដោយសមន្តចក្ខុ ដែលមិនទើសទាក់ក្នុងលោកទាំង ពួង ឬទ្រង់ឃើញរូបដែលកន្លងចក្ខុវិស័យរបស់សព្វសត្វ និងរូបដែលនៅ ខាងក្រៅជញ្ជាំងផ្ទះជាដើម ដោយមំសចក្ខុដ៏បរិសុទ្ធក្រៃលែង ទ្រង់ឃើញ ដោយបដិវេធប្បញ្ញាជាគ្រឿងត្រាស់ដឹង ដែលមានសមាធិជាបទដ្ឋាន (ជា ហេតុជិត) ដែលញុំាងប្រយោជន៍ខ្លួនឲ្យសម្រេច ទ្រង់ឃើញដោយទេសនា- បញ្ញាដែលជាគ្រឿងសម្ដែងធម៌ ដែលមានករុណាជាបទដ្ឋាន ដែលញុំាង ប្រយោជន៍អ្នកដទៃឲ្យសម្រេច ឬទ្រង់ដឹងធម៌ដែលធ្វើនូវអន្តរាយ ទ្រង់ឃើញ ធម៌ដែលជាហេតុនាំសត្វចេញចាកវដ្តទុក្ខ ឈ្មោះថា ទ្រង់ជាព្រះអរហន្ត ព្រោះទ្រង់កម្ចាត់សត្រូវ គឺ កិលេសចេញបាន ។ ទ្រង់ព្រះនាមថា សម្មា- សម្ពុទ្ធៈ ព្រោះត្រាស់ដឹងធម៌ដោយប្រពៃដោយព្រះអង្គឯង ព្រះអង្គត្រាស់

ធម៌ឯក ពិតមែនឬហ្ន៎ ។

បទថា **អភិសង្ខតំ** (តាក់តែងហើយ) សេចក្ដីថា ដែលភិក្ខុធ្វើហើយ គឺ ឲ្យកើតឡើងហើយ ។ បទថា **អភិសញ្ចេតយិតំ** (ត្រូវតាក់តែងហើយ) សេចក្ដីថា ដែលភិក្ខុគិត គឺ ឲ្យសម្រេចហើយ ។ បទថា **សោ តត្ថ ឋិតោ** (លោកទើបតាំងនៅក្នុង... នោះ) សេចក្ដីថា ភិក្ខុនោះតាំងនៅហើយក្នុងធម៌ គឺ សមថៈ និងវិបស្សនា ។ ដោយបទទាំងពីរថា **ធម្មរាគេន ធម្មនន្ទិយា** (ដោយសេចក្ដីពេញចិត្ត ត្រេកត្រអាលក្នុងធម៌នោះៗ) ព្រះអានន្ទពោលសេចក្ដីត្រេកអរ ដោយអំណាចសេចក្ដីពេញចិត្តក្នុងសមថៈ និងវិបស្សនា ។ ពិតណាស់ ភិក្ខុកាលកំណត់ឆន្ទរាគៈដោយប្រការទាំងពួង ក្នុងសមថៈ និងវិបស្សនា រមែងជាព្រះអរហន្ត ។ កាលមិនអាចកំណត់បានក៏ជាព្រះអនាគាមី រមែងកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ព្រោះលះបង់ឆន្ទរាគៈក្នុងសមថៈ និងវិបស្សនាមិនបាន នេះជាពាក្យរបស់អាចារ្យទាំងឡាយអ្នកមានការយល់ឃើញស្មើគ្នា ។ តែអាចារ្យដែលពេញចិត្តនិយាយឲ្យវេន្តងថា "ភិក្ខុនេះកើតហើយក្នុងសុទ្ធាវាសភូមិ ដោយអកុសលចិត្ត ព្រោះ

បាលីថា ព្រោះសេចក្ដីពេញចិត្តក្នុងធម៌នោះ ដូច្នេះ" ។ ចំណែកអាចារ្យអ្នកនិយាយឲ្យវង្វេង ត្រូវសួរថា "សូមលោកនាំព្រះសូត្រមកអាន" ។ កាលអាចារ្យនោះមើលមិនឃើញព្រះសូត្រដទៃ ក៏នាំចំពោះព្រះសូត្រនេះប៉ុណ្ណោះមកអាន ។ លំដាប់នោះ ក៏នឹងត្រូវជំទាស់ថា "ព្រះសូត្រនេះឬ ដែលលោកនាំមកអាន ក៏ឆ្លើយថា "នាំមកអានដោយពិត" ។ លំដាប់នោះ អាចារ្យដែលនិយាយឲ្យវង្វេងត្រូវជំទាស់ថា "បើដូច្នោះ ភិក្ខុដែលត្រូវការអនាគាមិផល នឹងត្រូវធ្វើសេចក្ដីត្រេកអរដោយអំណាចសេចក្ដីពេញចិត្ត ក្នុងសមថៈ និងវិបស្សនា កាលកើតឆន្ទរាគៈឡើងហើយ នឹងបានអនាគាមិផលឬ លោកកុំសម្ដែងពន្យាពេលថា ខ្ញុំបានអានសូត្រមកហើយឡើយ កាលសួរបញ្ហា គួរនឹងរៀនក្នុងសម្នាក់របស់អាចារ្យ ទំពារអត្ថរសឲ្យបែកហើយទើបសឹមពោល ព្រោះថា ឈ្មោះថា បដិសន្ធិក្នុងសួគ៌ដោយអកុសលមិនមាន និងបដិសន្ធិក្នុងអបាយដោយកុសលក៏មិនមាន ។

សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ទេវតាឬមនុស្ស ឬក៏ក្នុងសុគតិពួកណាមួយយ៉ាងដទៃ រមែងមិនប្រាកដដោយកម្ម

ដែលកើតពីលោភៈ ដែលកើតពីទោសៈ និងកើតពីមោហៈ ដោយពិត នរក កំណើតតិរច្ឆាន បេតវិស័យ ឬទុគ្គតិពួកណាមួយសូម្បីដទៃ រមែងប្រាកដដោយកម្ម ដែលកើតពីលោភៈ កើតពីទោសៈ និងកើតពីមោហៈ ។ អាចារ្យអ្នកនិយាយឲ្យវែងឆ្ងាយ ដែលបណ្ឌិតគប្បីធ្វើឲ្យយល់យ៉ាងនេះ ប្រសិនបើគេយល់សោត ក៏ចូរយល់ទៅចុះ តែបើគេមិនទាន់យល់ ក៏គប្បីបញ្ជូនគេទៅដោយពាក្យថា សូមលោកចូរទៅ ចូលទៅវិហារពីព្រឹក ហើយឆាន់បបរចុះ ។

បទថា អយម្បិ ខោ គហបតិ ។បេ។ ឯកធម្មោ សម្មទក្ខាតោ (គហបតី សូម្បីប្រការនេះ ក៏ជាធម៌ឯក ។ល។ ត្រាស់ទុកហើយដោយល្អ) សេចក្តីថា ព្រះអានន្ទ ត្រូវសួរដល់ធម៌ ១ ក៏ធ្វើធម៌ ១១ ប្រការ ឲ្យឈ្មោះថា ជាធម៌មួយៗ ដោយអំណាចពាក្យសួរ យ៉ាងនេះថា ធម៌មួយសូម្បីនេះ ព្រះមានព្រះភាគក៏ត្រាស់ទុកហើយ ធម៌មួយសូម្បីនេះ ព្រះមាន-ព្រះភាគក៏ត្រាស់ទុកហើយ ។

មយ៉ាងទៀត ការពោលថា សូម្បីធម៌ទាំងពួង ឈ្មោះថា ធម៌មួយ

ក៏គួរ ព្រោះអត្ថថា ឲ្យកើតអមតធម៌បាន ។

បទថា **និធិមុខំ គវេសន្តោ** (ស្វែងរកកំណប់ទ្រព្យ) បានដល់ស្វែងរកកំណប់ទ្រព្យ ។ បទថា **សកិទេវ** (តែមួយដង) បានដល់ ដោយសេចក្តីព្យាយាមតែមួយដងប៉ុណ្ណោះ ។

សួរថា ក៏ការជួបកំណប់ទ្រព្យ ១១ រណ្តៅ ដោយសេចក្តីព្យាយាមតែមួយដងប៉ុណ្ណោះ ដូចម្តេច ។

ឆ្លើយថា បុគ្គលខ្លះក្នុងលោកនេះ ត្រាច់ទៅក្នុងព្រៃ ស្វែងរកវត្ថុចិញ្ចឹមជីវិត បុគ្គលដែលប្រាថ្នាសេចក្តីល្អម្នាក់ ឃើញគេហើយ សួរថា លោកដ៏ចម្រើន ត្រាច់ទៅណា ។ គេឆ្លើយថា ស្វែងរកវត្ថុចិញ្ចឹមជីវិត អ្នកប្រាថ្នាសេចក្តីល្អនោះពោលថា បើដូច្នោះ លោកចូរមកនេះ លោកចូរលើកផ្ទាំងថ្មនេះឡើង ។ គេត្រឡប់ថ្មផែននោះឡើង ហើយក៏ជួបឆ្នាំងទ្រព្យ ១១ ឆ្នាំង ដែលដាក់ត្រួតលើគ្នា ឬដាក់រៀងគ្នា ។ យ៉ាងនេះ ឈ្មោះថា ជួបកំណប់ទ្រព្យ ១១ រណ្តៅ ដោយសេចក្តីព្យាយាមតែមួយដងប៉ុណ្ណោះ ។

បទថា **អាចរិយធនំ បរិយេសិស្សន្តិ** (ស្វែងរកទ្រព្យបូជាអាចារ្យ)

សេចក្តីថា ពិតហើយ អន្យតិរ្ថិយរៀនសិល្បៈក្នុងសម្នាក់អាចារ្យណា រមែង នាំទ្រព្យចេញចាកផ្ទះមកឲ្យអាចារ្យនោះមុន ឬក្រោយ ឬក្នុងរវាងការរៀន សិល្បៈ តិរ្ថិយដែលមិនមានទ្រព្យក្នុងផ្ទះ ក៏រមែងស្វែងរកពីញាតិ ឬពី សម្លាញ់ឲ្យ សូម្បីកាលអ្នកទាំងនោះមិនមាន រមែងស្វែងរកពីអ្នកដែលរាប់ អានគ្នារបស់ជនទាំងនោះ កាលមិនបាន រមែងដើរសូមគេឲ្យក៏មាន ទសម-គហបតី ពោលសំដៅយកប្រការនោះ ទើបពោលពាក្យនេះ ។

បទថា **កឹ បនាហំ** (ចំណែកខ្ញុំ... យ៉ាងណាហ្ន៎) សេចក្តីថា ទសមគហបតីពោលថា មុនដំបូងពួកអន្យតិរ្ថិយក្រៅសាសនា ស្វែងរក ទ្រព្យដើម្បីអាចារ្យអ្នកឲ្យត្រឹមតែសិល្បៈ ក្នុងសាសនាដែលមិននាំសត្វចេញ ចាកទុក្ខ តែយើងនឹងមិនធ្វើការបូជាដល់អាចារ្យអ្នកសម្តែងវត្តបដិបត្តិ ឲ្យ កើតអមតៈ ១១ ប្រការ ក្នុងសាសនាដែលនាំសត្វចេញចាកទុក្ខ មានប្រការ យ៉ាងនោះ ឬថានឹងធ្វើហ្ន៎ ។ បទថា **បច្ចេកទុស្សយុគេន អច្ឆាទេសិ** (និមន្តភិក្ខុមួយរូបៗ ឲ្យស្លៀកដណ្តប់ដោយគូនៃសំពត់) សេចក្តីថា ទស-មគហបតី បានថ្វាយគូសំពត់ដល់ភិក្ខុមួយរូប ១ គូ ។ ក៏ក្នុងរឿងនេះ

*ពាក្យដែលនិយាយឡើង រមែងមានដូច្នេះ ព្រោះដូច្នោះ លោកទើបពោលថា ឲ្យស្មៀកដណ្ដប់សំពត់ ។ បទថា* ***បញ្ចសតំ វិហារំ*** *(វិហារតម្លៃ ៥០០ សេចក្ដីថា ឲ្យសាងបណ្ណសាលាមានតម្លៃ ៥០០ កហាបណៈ ។*

ចប់អដ្ឋកថា ឧសមសូត្រទី ៦

# អដ្ឋកថា គោបាលកសូត្រទី ៧

## អង្គ ១១ របស់អ្នកចិញ្ចឹមគោ

*គប្បីជ្រាបវិនិច្ឆ័យក្នុង គោបាលកសូត្រទី ៧ ដូចតទៅនេះ ៖*

*[១២៤] មានកថា ៣ គឺ ឯកនាឡិកាកថា ១ ចតុរស្សកថា ១ និសិន្នវត្តិកាកថា ១ ។ ក្នុងកថា ៣ នោះ ការពោលបាលីហើយ ពោលសេចក្តីនៃបទទៅម្តងមួយបទ ឈ្មោះថា* ***ឯកនាឡិកាកថា*** *, ការពោលចងជា ៤ បទ ដូច្នេះថា នាយគោបាលដែលមិនឆ្លាត ភិក្ខុដែលមិនឆ្លាត នាយគោបាលដែលឆ្លាត ភិក្ខុដែលឆ្លាត ឈ្មោះថា* ***ចតុរស្សកថា*** *, កថាយ៉ាងនេះគឺ ការសម្តែងនាយគោបាលអ្នកមិនឆ្លាតដរាបដល់ចប់ ការសម្តែងភិក្ខុដែលមិនឆ្លាតដរាបដល់ចប់ , ការសម្តែងនាយគោបាលអ្នកឆ្លាត ដរាបដល់ចប់ ការសម្តែងភិក្ខុដែលឆ្លាតដរាបដល់ចប់ ឈ្មោះថា* ***និសិន្នវត្តិកាកថា*** *។ កថានេះ គ្រប់អាចារ្យក្នុងព្រះសាសនានេះ ធ្លាប់ប្រព្រឹត្តមកហើយ ។*

*បទថា ឯកាទសហិ ភិក្ខវេ អង្គេហិ (ម្នាលភិក្ខុទាំងឡាយ ដោយ*

អង្គ ១១ ប្រការ) បានដល់ ដោយចំណែកដែលមិនមែនគុណ ១១ ប្រការ ។ បទថា **គោគណំ** ប្រែថា ហ្វូងគោ ។ បទថា **បរិហរិតុំ** (ដើម្បីនឹងចិញ្ចឹម) បានដល់ ដើម្បីនឹងនាំដើរទៅ ។ បទថា **ផាតិកាតុំ** (ដើម្បីឲ្យបរេម្រើន) បានដល់ ដើម្បីឲ្យដល់សេចក្តីធំធាត់ ។

បទថា **ឥធ** ប្រែថា ក្នុងលោកនេះ ។ បទថា **ន រូបញ្ញូ ហោតិ** (រមែងមិនស្គាល់រូប) សេចក្តីថា រមែងមិនស្គាល់រូបដោយចំនួន ឬដោយពណ៌ា រមែងមិនដឹងការរាប់ថា គោរបស់ខ្លួនមាន ១០០ ក្បាល ឬ ១.០០០ ក្បាល ឈ្មោះថា រមែងមិនដឹងដោយចំនួន ។ នាយគោបាលនោះ កាលគោទាំងឡាយត្រូវលួច ឬបាត់ ក៏រាប់ហ្វូងគោរបស់ខ្លួន ដឹងថា ថ្ងៃនេះមេគោចំនួនប៉ុណ្ណោះ មិនឃើញ ក៏ដើររករហូតអស់ ២-៣ ស្រុក ឬតាមព្រៃ ក៏រកមិនឃើញ កាលមេគោរបស់អ្នកដទៃចូលទៅក្នុងហ្វូងគោរបស់ខ្លួន ក៏ដឹងថា មេគោចំនួនប៉ុណ្ណោះមិនមែនរបស់ខ្លួន ក៏យកឈើដេញកៀងទៅ ។ មេគោទាំងឡាយរបស់នាយគោបាលនោះដែលបាត់ទៅ ក៏រមែងវិនាសទៅ ។ នាយគោបាលក៏ដេញមេគោរបស់អ្នកដទៃទៅ ។ ម្ចាស់គោ

ឃើញក៏គម្រាមថា នេះជាមេគោរបស់យើង យើងរីតទឹកដោះអស់វេលាប៉ុណ្ណេះ ហើយក៏នាំមេគោរបស់ខ្លួនទៅ សូម្បីហ្វូងគោរបស់គេក៏ថយចុះ ។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកការបរិភោគបញ្ចគោរស ។ នាយគោបាលមិនដឹងថា មេគោចំនួនប៉ុណ្ណេះ ពណ៌ក្រហមចំនួនប៉ុណ្ណេះ ពណ៌សប៉ុណ្ណេះ ពណ៌ខ្មៅប៉ុណ្ណេះ ពណ៌ស្រស់ប៉ុណ្ណេះ ពណ៌ក្រហមស្រទន់ប៉ុណ្ណេះ ឈ្មោះថា មិនស្គាល់ដោយពណ៌ នាយគោបាលនោះ កាលមេគោទាំងឡាយត្រូវលួច ឬបាត់ ។បេ។ រមែងជាអ្នកឃ្លាតឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា **ន លក្ខណកុសលោ ហោតិ** (មិនឈ្លាសក្នុងលក្ខណៈ) សេចក្តីថា រមែងមិនដឹងគ្រឿងចំណាំផ្សេងៗ មានធ្នូ លំពែង និងស្នា ជាដើម ដែលគេធ្វើទុកត្រង់ខ្លួនរបស់មេគោទាំងឡាយ កាលណាត្រូវលួចទៅ ឬបាត់ទៅ គេគិតថា ថ្ងៃនេះ គោមានលក្ខណៈឯណោះ និងគោមានលក្ខណៈឯណោះមិនឃើញ ។បេ។ រមែងជាអ្នកឃ្លាតឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា **ន អាសាដិកំ សាដេតា** (មិនកម្ចាត់ពងរុយ) សេចក្តីថា

គោទាំងឡាយរមែងមានដំបៅ ក្នុងទីដែលត្រូវដង្គត់ និងបន្ទាជាដើមមុត រុយក្បាលខៀវ រមែងពងដាក់ក្នុងទីមានដំបៅនោះ ពងរបស់រុយទាំងនោះ ឈ្មោះថា ពងរុយ ។ គប្បីប្រើឈើគ្កឹះពងរុយនោះចេញ ហើយដាក់ថ្នាំ ។ នាយគោបាលល្ងង់ មិនធ្វើយ៉ាងនោះ ។ ព្រោះហេតុនោះ ទើបត្រាស់ថា **មិនកម្ចាត់ពងរុយ** ។ ដំបៅគោរបស់គេ រមែងរីកជ្រៅ ដង្កូវទាំងឡាយក៏ចូលពោះ ។ គោទាំងឡាយក៏មានជម្ងឺ មិនអាចនឹងស៊ីស្មៅ ផឹកទឹកបានតាមត្រូវការ ។ ទឹកដោះរបស់គោទាំងឡាយក្នុងឋានៈនោះ រមែងខះទៅ ។ កាពរហ័សរហួនរបស់គោក៏ថយចុះ ។ អន្តរាយនៃជីវិតរបស់គោទាំងពីរពួកនោះក៏រមែងមាន ។ សម្បូហ្វូងគោរបស់គេរមែងថយចុះ ដោយប្រការដូច្នេះ ។ល។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកបញ្ចគោរស ។

បទថា **ន វណំ បដិច្ឆាទេតា ហោតិ (មិនបិទដំបៅ)** សេចក្ដីថា គប្បីដាក់ថ្នាំត្រង់ដំបៅដែលកើតដល់គោ ដោយន័យដូចពោលហើយ ចងបិទដោយសំបកឈើ្ម ឬសំពត់ ។ នាយគោបាលល្ងង់មិនធ្វើដូច្នោះ ។ តពីនោះ ខ្ទុះរមែងហូរចេញពីដំបៅគោរបស់គេ ។ មេគោទាំងនោះ រមែងត្រដុស

នូវគ្នានិងគ្នា ព្រោះហេតុនោះ ដំបៅគោពួកដទៃក៏កើតឡើង ។ គោទាំងឡាយក៏មានជំងឺការដោយអាការយ៉ាងនេះ មិនអាចស៊ីស្មៅ ផឹកទឹកបានតាមសេចក្ដីត្រូវការ ។ល។ គេក៏ជាអ្នកឃ្លាតឆ្ងាយចាកការបរិភោគបញ្ច-គោរស ។

បទថា ន ធូមំ កត្តា ហោតិ (មិនបំពក់ភ្លើង) សេចក្ដីថា ក្នុងពេលមុនភ្លៀង ជាវេលាដែលសម្បូរទៅដោយសត្វល្អិត មានរបោម និងមូសជាដើម កាលហ្វូងគោចូលក្រោល នាយគោបាលគប្បីបំពក់ផ្សែងជិតៗក្រោលនោះ ។ នាយគោបាលមិនឆ្លាត មិនធ្វើដូច្នោះ ហ្វូងគោត្រូវសត្វល្អិត មានរបោមជាដើម រុកកួនរហូតអស់មួយយប់ទល់ភ្លឺ មិនបានដេកព្រឹកឡើងទៅដេកឯគល់ឈើជាដើមនោះៗ ក្នុងព្រៃ គោទាំងនោះក៏មិនអាចស៊ីស្មៅ និងផឹកទឹកបានតាមត្រូវការ ។ល។ នាយគោបាលនោះ ក៏ឃ្លាតចាកពីការបរិភោគបញ្ចគោរស ។

បទថា ន តិត្ថំ ជានាតិ (មិនដឹងកំពង់ទឹក) សេចក្ដីថា រមែងមិនដឹងកំពង់រាបស្មើ ឬមិនរាបស្មើ មានសត្វកាច ឬមិនមានសត្វកាច នាយ

គោបាលនោះ រមែងឲ្យមេគោចុះក្នុងទីមិនមែនកំពង់ កាលមេគោទាំងនោះជាន់ផ្ទាំងថ្មជាដើមក្នុងទីមិនរាបស្មើ ជើងក៏បែក ។ សត្វកាចមានក្រពើជាដើម រមែងចាប់មេគោដែលចុះកំពង់ទឹកជ្រៅមានសត្វកាច ។ គោទាំងឡាយក៏នឹងត្រូវគេពោលថា "ថ្ងៃនេះគោបាត់ចំនួនប៉ុណ្ណេះ ថ្ងៃនេះគោបាត់ចំនួនប៉ុណ្ណេះ" ។ សូម្បីហ្វូងគោរបស់នាយគោបាលនោះ រមែងថយចុះដោយប្រការដូច្នេះ ។ល។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកបញ្ចគោរស ។

បទថា ន បីតំ ជានាតិ (មិនដឹងគោស៊ីផឹក) សេចក្តីថា រមែងមិនដឹងថា គោស៊ីផឹកហើយឬនៅ ពិតណាស់ នាយគោបាលគួរនឹងដឹងថា គោស៊ីផឹកហើយ ឬមិនទាន់បានស៊ី យ៉ាងនេះថា មេគោនេះស៊ីផឹកហើយ មេគោនេះមិនទាន់បានស៊ីផឹក មេគោនេះបានឱកាសត្រង់កំពង់ស៊ីផឹក មេគោនេះមិនបានឱកាស ។ ក៏នាយគោបាលនេះ រក្សាហ្វូងគោក្នុងព្រៃកន្លះថ្ងៃហើយគិតថា នឹងឲ្យវាស៊ីផឹក ក៏នាំទៅកាន់ស្ទឹង ឬបឹង ។ ក្នុងទីនោះ គោមេហ្វូង និងគោកូនហ្វូង និងមេគោមានកម្លាំង ក៏នឹងយកស្នែងជល់គោដែលមានកម្លាំងខ្សោយ និងធ្វើឱកាសឲ្យដល់ខ្លួន ហើយចុះទឹកត្រឹមទ្រូង

ស៊ីផឹកតាមសប្បាយ ។ គោក្រៅពីនោះ កាលមិនបានឱកាសក៏ឈរត្រង់ប្រាំង ផឹកទឹកលាយភក់ ឬមិនផឹក ។ ពេលនោះ នាយគោបាលនោះ ក៏នឹងវាយត្រង់ខ្នងដេញចូលព្រៃទៅទៀត មេគោដែលមិនបានស៊ីផឹកក្នុងទីនោះ ក៏នឿយហត់ទន់ខ្សោយកម្លាំង ព្រោះស្រេកទឹក ក៏ស៊ីស្មៅតាមសេចក្តីត្រូវការមិនបាន ។ ក្នុងឋានៈនោះ ទឹកដោះរបស់គោទាំងឡាយក៏ខះទៅ ភាពរហ័សរហួនរបស់គោទាំងឡាយក៏ថយចុះ ។ល។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា **ន វីថឹ ជានាតិ** (មិនដឹងផ្លូវ) សេចក្តីថា រមែងមិនដឹងថាផ្លូវនេះរាបស្មើរួចផុតភ័យ ផ្លូវនេះមិនរាបស្មើ គួរវៀស គួរមានភ័យ នាយគោបាលនោះ វៀរផ្លូវដែលរាបស្មើ និងរួចផុតភ័យ ឲ្យហ្វូងគោដើរទៅផ្លូវក្រៅពីនេះ ។ ក្នុងទីនោះ គោទាំងឡាយបានក្លិនរាជសីហ៍ និងខ្លាជាដើម និងអន្តរាយអំពីចោរគំរាម ប្រឈមមុខនឹងសត្វកាចចោម ឈរងើយ.កមិនស៊ីស្មៅ មិនផឹកទឹកតាមត្រូវការ ក្នុងឋានៈនោះ ទឹកដោះរបស់គោនោះក៏ខះទៅ ។ល។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកការបរិភោគបញ្ច-

គោរស ។

បទថា ន គោចរកុសលោ ហោតិ (មិនឆ្លាតក្នុងទីរកស៊ី) សេចក្តីថា ក៏នាយគោបាលគប្បីជាអ្នកឆ្លាតក្នុងគោចរ គប្បីដឹង ៥ ថ្ងៃម្តង ឬ ៧ ថ្ងៃម្តង ដេញគោទៅទិសមួយ ថ្ងៃស្អែកមិនគប្បីដេញទៅក្នុងទិសនោះ ព្រោះថា ទីដែលគោហ្វូងធំត្រាច់មកហើយ រមែងស៊ីអស់គ្មានសល់ ដូចផ្ទៃស្គរ មិនមានស្មៅ សូម្បីតែទឹកក៏ល្អក់ ព្រោះដូច្នោះ ក្នុងថ្ងៃទី ៥ ឬទី ៧ នាយគោបាលទើបគួរដេញទៅក្នុងទីនោះទៀត ដោយហេតុប៉ុណ្ណេះ ទាំងស្មៅក៏ត្រឡប់ដុះឡើង ទាំងទឹកក៏ថ្លា ។ ក៏នាយគោបាលនេះ មិនដឹងការឃ្វាលគោទៅក្នុងមួយដង ៥ ថ្ងៃ ឬ ៧ ថ្ងៃយ៉ាងនេះ រមែងចិញ្ចឹមគោក្នុងទីដែលឃ្វាលហើយរាល់ៗ ថ្ងៃ ។ ដូច្នោះ ហ្វូងគោរបស់នាយគោបាល ក៏មិនបានស៊ីស្មៅស្រស់ ស៊ីតែស្មៅស្ងួត ផឹកតែទឹកលាយភក់ ។ ក្នុងឋានៈនោះ ទឹកដោះរបស់គោទាំងឡាយក៏ខះទៅ ។ល។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកការបរិភោគបញ្ចគោរស ។

បទថា អនវសេសទោហី ហោតិ (រីតទឹកដោះមិនឲ្យសល់) សេចក្តី

ថា ក៏នាយគោបាលដែលឆ្លាត គប្បីរឹតទឹកដោះឲ្យនៅសល់ វៀរទឹកដោះទុកមួយកន្សោម ឬពីរកន្សោម ល្មមនឹងកូនគោនៅជៅបាន ។ នាយគោបាលនេះ រឹតមិនទុកឲ្យសល់សម្រាប់កូនគោឡើយ ។ កូនគោដែលនៅជៅដោះ ក៏នឹងស្គមស្លេកស្លាំង ព្រោះឃ្លានទឹកដោះ មិនអាចតាំងនៅបាន ។ ដួលស្លាប់ចំពោះមុខមេ មេឃើញកូនតូច គិតថា កូនយើងមិនបានជៅដោះរបស់ខ្លួន ដោយសេចក្តីសោយសោក ក៏ស៊ីស្មៅផឹកទឹកមិនបានតាមត្រូវការ ទឹកដោះក្នុងកន្សោមដោះទាំងឡាយក៏ខះទៅ សូម្បីហ្វូងគោរបស់នាយគោបាលនោះក៏ថយចុះ ។ល។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកបញ្ចគោរស ។

ឈ្មោះថា **គោបិតរ** ព្រោះធ្វើនាទីជាបានៃគោទាំងឡាយ ឈ្មោះថា **គោបរិនាយក** ព្រោះរក្សាគោទាំងឡាយ គឺ នាំទៅតាមពេញចិត្ត ។ បទថា **តេ ន អតិរេកបូជាយ (មិនបូជាគោទាំងឡាយ... ដោយការបូជាដ៏ក្រៃលែង)** សេចក្តីថា នាយគោបាលឆ្លាត រមែងបូជាគោឧសភៈបែបនោះ ដោយការបូជាដ៏ក្រៃលែង រមែងឲ្យអាហារគោដ៏ប្រណីត ។ រមែងប្រដាប់ដោយគ្រឿងប្រដាប់ ប្រោះនូវរបស់ក្រអូប ប្រដាប់កម្រងផ្កា ពាក់កងមាស

កងប្រាក់ត្រង់ជើង តាំងប្រទីបទុករហូតអស់យប់ ឲ្យដេកខាងក្រោមពិតាន សំពត់ ។ ក៏នាយគោបាលនេះ រមែងមិនធ្វើសក្ការៈសូម្បីតែមួយ អំពីសក្ការៈនោះ ពួកគោឧសភៈ កាលមិនបានការបូជាយ៉ាងនោះ ក៏មិនរក្សាហ្វូងគោ រមែងមិនការពារអន្តរាយ សូម្បីហ្វូងគោរបស់នាយគោបាលនោះ រមែងថយចុះដោយអាការយ៉ាងនេះ ។ល។ គេរមែងជាអ្នកឃ្លាតឆ្ងាយចាកបញ្ចគោរស ។

បទថា ឥធ បានដល់ ក្នុងសាសនានេះ ។ បទថា **ន រូបញ្ញូ ហោតិ (រមែងមិនស្គាល់រូប)** សេចក្តីថា រមែងមិនដឹងរូបដែលត្រាស់ទុកដោយអាការ ២ យ៉ាងនេះ គឺ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ ដោយការរាប់ ឬដោយសមុដ្ឋាន ។ ភិក្ខុដែលមិនឆ្លាត រមែងមិនដឹងថា ចំណែកនៃរូបមាន ២៥ ដែលមកក្នុងព្រះបាលីយ៉ាងនេះ គឺ អាយតនៈ គឺ ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយៈ រូបៈ សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ (បរិច្ឆេទរូប) អាបោធាតុ រូបស្សលហុតា (រូបស្រាល) រូបស្ស-

មុទុតា (ភាពទន់នៃរូប) រូបស្សកម្មញ្ញតា (រូបគួរដល់ការងារ) រូបស្ស-ឧបចយៈ (ការកើតឡើងនៃរូប) រូបស្សសន្តតិ (ការបន្តនៃរូប) រូបស្ស-ជរតា (រូបជរា) រូបស្សអនិច្ចតា (ការបែកធ្លាយនៃរូប) កវឡិង្ការាហារ (អាហារ គឺ ដុំបាយ) ឈ្មោះថា មិនដឹងដោយការរាប់ ។ ភិក្ខុនោះ កាល មិនដឹងរូបដោយការរាប់ កំណត់រូបហើយ កំណត់អរូប (នាម) ហើយ កំណត់រូប និងនាម កំណត់បច្ច័យ លើកឡើងកាន់លក្ខណៈ មិនអាចឲ្យ កម្មដ្ឋានដល់ទីបំផុតបាន ។ ភិក្ខុនោះ រមែងមិនចម្រើនដោយសីល សមាធិ វិបស្សនា មគ្គ ផល និងនិព្វានក្នុងសាសនានេះ ដូចហ្វូងគោរបស់នាយ គោបាលនោះ មិនចម្រើនឡើង ដូច្នោះ ។ មួយទៀត ភិក្ខុនោះ រមែងជា អ្នកឃ្លាតឆ្ងាយចាកធម្មក្ខន្ធ ៥ គឺ សីលក្ខន្ធដែលជាអសេក្ខៈ សមាធិខន្ធ បញ្ញាខន្ធ វិមុត្តិខន្ធ និងវិមុត្តិញ្ញាណទស្សនខន្ធ ដែលជាអសេក្ខៈ ដូចនាយ គោបាលនោះ ជាអ្នកឃ្លាតឆ្ងាយចាកបញ្ចគោរស ដូច្នោះ ភិក្ខុនោះរមែង មិនដឹងថា រូបមានប្រមាណប៉ុណ្ណេះ មានសមុដ្ឋានមួយ រូបមានប្រមាណ ប៉ុណ្ណេះមានសមុដ្ឋាន ២ , រូបមានប្រមាណប៉ុណ្ណេះមានសមុដ្ឋាន ៣ រូប

មានប្រមាណប៉ុណ្ណេះ មានសមុដ្ឋាន ៤ , រូបមានប្រមាណប៉ុណ្ណេះ មិនកើតពីសមុដ្ឋានណាៗ ឈ្មោះថា មិនដឹងដោយសមុដ្ឋាន ។ ភិក្ខុនេះ ក៏ប្រៀបផ្ទឹមដូចនាយគោបាលនោះ រមែងមិនស្គាល់រូបរបស់គោទាំងឡាយដោយពណ៌ ។ ភិក្ខុនោះ កាលមិនដឹងរូបដោយសមុដ្ឋាន កំណត់រូបហើយកំណត់អរូប (នាម) ។ល។ រមែងជាអ្នកឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា **ន លក្ខណកុសលោ ហោតិ (មិនឆ្លាតក្នុងលក្ខណៈ)** សេចក្តីថា ភិក្ខុរមែងមិនដឹងកុសលធម៌ និងអកុសលធម៌ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា បុគ្គលពាលមានកម្មជាលក្ខណៈ បុគ្គលជាបណ្ឌិតមានកម្មជាលក្ខណៈ ដូច្នេះថា លក្ខណៈរបស់បុគ្គលដែលជាពាល និងជាបណ្ឌិត ។ ភិក្ខុនោះ កាលមិនដឹងយ៉ាងនេះ វៀរជនពាលហើយ រមែងមិនសេពបណ្ឌិត កាលវៀរជនពាលមិនសេពបណ្ឌិត ឈ្មោះថា រមែងមិនដឹងវត្ថុដែលគួរ និងមិនគួរ ។ កម្មដែលជាអកុសល និងអកុសល កម្មដែលមានទោស និងមិនមានទោស កម្មធ្ងន់ និងស្រាល កម្មដែលកែខៃបាន និងកែខៃមិនបាន ហេតុ និងមិនមែនហេតុ កាលមិនដឹងដូច្នោះ ទទួល

កម្មដ្ឋានហើយ ក៏មិនអាចឲ្យចម្រើនបាន ។ ភិក្ខុនោះ រមែងមិនចម្រើនដោយសីលជាដើម តាមដែលពោលហើយក្នុងព្រះសាសនានេះ ដូចហ្វូងគោរបស់នាយគោបាលមិនឆ្លាត មិនលូតលាស់ឡើងបាន ដូច្នោះ ។ ភិក្ខុនោះរមែងជាអ្នកឃ្លាតចាកធម្មក្ខន្ធ ៥ ដូចនាយគោបាលមិនឆ្លាតនោះឃ្លាតចាកបញ្ចគោរស ដូច្នោះ ។

បទថា ន អាសាដិកំ សាដេតា ហោតិ (មិនគ្ចឹះពងរុយ) សេចក្តីថា ភិក្ខុមិនបន្ទោបង់កាមវិតក្កៈជាដើម ដែលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះថា កាមវិតក្កៈកើតឡើងហើយ ។ ភិក្ខុនោះមិនធ្វើអកុសលវិតក្កៈនេះឲ្យអស់ ជាអ្នកធ្លាក់នៅក្នុងអំណាចនៃវិតក្កៈត្រាច់ទៅ ទទួលកម្មដ្ឋានហើយ ក៏មិនអាចឲ្យចម្រើនបាន ។ ភិក្ខុនោះ រមែងជាអ្នកឃ្លាតឆ្ងាយ ។ល។ ដូចហ្វូងគោរបស់នាយគោបាលនោះ ដូច្នោះ ។

បទថា ន វណំ បដិច្ឆាទេតា ហោតិ (មិនបិទដំបៅ) សេចក្តីថា ភិក្ខុនោះ កាន់យកនិមិត្តក្នុងអារម្មណ៍ទាំងពួង ដោយន័យមានជាអាទិ៍ថា ភិក្ខុឃើញរូបដោយចក្ខុហើយ ជាអ្នកកាន់យកដោយនិមិត្ត ដូច្នេះ រមែង

មិនញ៉ាំងសេចក្តីសង្រួមឲ្យដល់ព្រម ដូចនាយគោបាលអ្នកមិនច្លាតនោះ មិនបិទដំបៅ ដូច្នោះ ។ ភិក្ខុនោះ ជាអ្នកបើកទ្វារហើយត្រាច់ទៅ (មិនសង្រួម) ទទួលកម្មដ្ឋានហើយ ក៏មិនធ្វើឲ្យចម្រើនបាន ។បេ។ រមែងជាអ្នកឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា ន ធូមំ កត្តា ហោតិ (មិនបំពក់ភ្លើង) សេចក្តីថា ភិក្ខុរមែងមិនធ្វើការបំពក់ផ្សែង គឺ ធម្មទេសនា មិនពោលនូវធម៌ មិនសូត្រសរភញ្ញ មិនអង្គុយសន្ទនាធម៌ មិនធ្វើអនុមោទនា ដូចនាយគោបាលមិនបំពក់ផ្សែងភ្លើង ។ តពីនោះ មនុស្សទាំងឡាយក៏មិនស្គាល់ភិក្ខុនោះថាភិក្ខុនេះជាពហុស្សូត ជាអ្នកមានគុណធម៌ ដូច្នេះ ។ មនុស្សទាំងនោះកាលមិនដឹងគុណ ឬមិនមែនគុណ ក៏មិនធ្វើការសង្គ្រោះដោយបច្ច័យ ៤ ។ ភិក្ខុនោះ កាលលំបាកដោយបច្ច័យទាំងឡាយ រមែងមិនអាចធ្វើការស្វាធ្យាយព្រះពុទ្ធវចនៈ មិនអាចបំពេញវត្តបដិបត្តិឲ្យបរិបូរណ៍ ទទួលកម្មដ្ឋានហើយរមែងមិនអាចឲ្យចម្រើនបាន ។បេ។ រមែងជាអ្នកឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា ន តិត្ថំ ជានាតិ (មិនស្គាល់កំពង់ទឹក) សេចក្តីថា ភិក្ខុនោះ

រមែងមិនចូលទៅរកភិក្ខុដែលជាពហុស្សូតទាំងឡាយ ដែលដូចជាកំពង់ទឹក កាលមិនចូលទៅរក រមែងមិនបានសាកសួរ រមែងមិនបានសួរយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន នឹងគប្បីបំពេញព្យញ្ជនៈនេះឲ្យបរិបូរណ៍បានយ៉ាងណា ភាសិតនេះមានអត្ថយ៉ាងណា ក្នុងទីនេះបាលីពោលយ៉ាងណា ក្នុងទីនេះមានអធិប្បាយយ៉ាងណា ក្នុងទីនេះអត្ថសម្ដែងអ្វី ។ អធិប្បាយថា រមែងមិនធ្វើឲ្យគេយល់ ។ ភិក្ខុដែលជាពហុស្សូតទាំងនោះ ដែលភិក្ខុនោះមិនបានសួរយ៉ាងនេះ រមែងមិនប្រាប់ធម៌ដែលមិនទាន់បានប្រាប់ រមែងមិនសម្ដែងបែកធម៌ រមែងមិនធ្វើសេចក្ដីដែលរាក់ឲ្យរាក់ឡើង និងរមែងមិនធ្វើធម៌ដែលមិនប្រាកដ ឲ្យប្រាកដ និងរមែងមិនបន្ទោបង់សេចក្ដីសង្ស័យត្រឹមតែមួយក្នុងបណ្ដាសេចក្ដីសង្ស័យដែលមានច្រើនប្រការ ក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃសេចក្ដីសង្ស័យដែលមានច្រើនយ៉ាង ។ ពិតហើយ សេចក្ដីសង្ស័យនុ៎ះឯង ឈ្មោះថា ធម៌ជាទីតាំងនៃសេចក្ដីសង្ស័យ បណ្ដាសេចក្ដីសង្ស័យទាំងនោះ សូម្បីតែមួយក៏មិនបាននាំចេញ ។ ភិក្ខុនោះ មិនចូលទៅរកកំពង់ទឹក គឺ ភិក្ខុជាពហុស្សូតយ៉ាងនេះ ក៏នៅមានសេចក្ដីសង្ស័យ ទទួលកម្មដ្ឋាន

ហើយ មិនអាចឲ្យចម្រើនបាន ។ មួយវិញទៀត ភិក្ខុនេះ រមែងមិនដឹងកំពង់ទឹក គឺ ធម៌ ដូចនាយគោបាលនោះមិនស្គាល់កំពង់ទឹក កាលមិនដឹង រមែងសួរបញ្ហាក្នុងទីមិនមែនវិស័យ ចូលទៅរកភិក្ខុដែលជំនាញអភិធម្ម ក៏សួរវិន័យ ដែលជាកប្បិយៈ និងអកប្បិយៈ ។ ចូលទៅរកព្រះវិន័យធរ ក៏សួរដល់ការកំណត់នាម និងរូប ។ ភិក្ខុទាំងនោះ ក៏មិនអាចតបពាក្យសួរក្នុងទីមិនមែនវិស័យបាន ។ ភិក្ខុនោះ ជាអ្នកមានសេចក្តីសង្ស័យនៅជាប់ខ្លួន ទទួលកម្មដ្ឋានហើយ ក៏មិនអាចធ្វើឲ្យចម្រើនបាន ។ល។ រមែងជាអ្នកឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា **ន បីតំ ជានាតិ (មិនដឹងធម៌ដែលស្តាប់ហើយ)** សេចក្តីថា ភិក្ខុនោះ រមែងមិនដឹង រមែងមិនបានសេចក្តីបាមោជ្ជៈដែលអាស្រ័យធម៌ ដូចនាយគោបាលមិនដឹងថា គោទាំងឡាយផឹកទឹកហើយ ឬមិនទាន់បានផឹក ដូច្នោះ រមែងមិនបានអានិសង្ស អាស្រ័យបុញ្ញកិរិយាវត្ថុដែលសម្រេចអំពីការស្តាប់ ។ គ្រាទៅកាន់សាលាស្តាប់ធម៌ មិនស្តាប់ដោយគោរព ត្រឡប់ជាអង្គុយងោក និយាយច្រើន បញ្ជូនចិត្តទៅក្នុងទីដទៃ ។ ភិក្ខុនោះ កាល

មិនស្តាប់ធម៌ដោយគោរព ទទួលកម្មដ្ឋានហើយ ក៏មិនអាចធ្វើឲ្យចម្រើនបាន ។ល។ រមែងជាអ្នកឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា ន វីថឹ ជានាតិ (មិនដឹងផ្លូវ) សេចក្តីថា ភិក្ខុនោះ រមែងមិនដឹងច្បាស់តាមសេចក្តីពិត នូវអរិយមគ្គដែលប្រកបដោយអង្គ ៨ ថា ផ្លូវនេះជាលោកិយៈ ផ្លូវនេះជាលោកុត្តរៈ ដូច្នេះ ដូចនាយគោបាលមិនដឹងផ្លូវ និងមិនមែនផ្លូវ ដូច្នោះ ។ កាលមិនដឹងផ្លូវ ប្រកាន់មាំផ្លូវដែលជាលោកិយៈហើយ មិនអាចធ្វើផ្លូវដែលជាលោកុត្តរៈ ឲ្យកើតបាន ។ល។ រមែងជាអ្នកឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា ន គោចរកុសលោ ហោតិ (មិនឆ្លាតក្នុងទីគោចរ) សេចក្តីថា ភិក្ខុនោះ រមែងមិនដឹងតាមសេចក្តីពិតនូវសតិប្បដ្ឋាន ៤ ថា ទាំងនេះជាលោកិយៈ ទាំងនេះជាលោកុត្តរៈ ដូចនាយគោបាលអ្នកមិនដឹងការកៀងគោទៅម្តង ៥ ថ្ងៃ ៧ ថ្ងៃ កាលមិនដឹង មិនបង្អោនញាណរបស់ខ្លួនចូលទៅក្នុងកម្មដ្ឋានដែលល្អិតសុខុម ប្រកាន់ក្នុងសតិប្បដ្ឋានដែលជាលោកិយៈ ក៏មិនអាចធ្វើសតិប្បដ្ឋានដែលជាលោកុត្តរៈឲ្យកើតបាន ។ល។ រមែងជាអ្នក

ឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា **អនវសេសទោហី ហោតិ (រីតទឹកដោះមិនឲ្យមានសល់)** សេចក្ដីថា ភិក្ខុនោះ កាលមិនដឹងប្រមាណក្នុងការទទួល ឈ្មោះថា រមែង រីតទឹកដោះមិនឲ្យនៅសល់ ។ ក៏ក្នុងនិទ្ទេសវារៈនៃបទនោះ មានអធិប្បាយ ដូចតទៅនេះ ។ បទថា **អភិហដ្ឋុំ បវារេន្តិ (បវារណាដើម្បីនាំទៅបាន តាមពេញចិត្ត)** សេចក្ដីថា នាំទៅចំពោះទីបវារណា ។

ការនាំទៅដោយចំពោះ មាន ២ យ៉ាង គឺ ការនាំទៅចំពោះ ដោយវាចា ១ ការនាំទៅចំពោះដោយបច្ច័យ ១ ។ មនុស្សទាំងឡាយទៅ កាន់សំណាក់របស់ភិក្ខុ រមែងបវារណាថា លោកម្ចាស់ មានសេចក្ដីត្រូវ ការវត្ថុណា ចូរប្រាប់ ឈ្មោះថា ការនាំទៅចំពោះដោយវាចា ។ មនុស្ស ទាំងឡាយកាន់យកសំពត់ ឬទឹកដោះថ្លា និងទឹកដោះខាប់ជាដើម ទៅកាន់ សំណាក់របស់ភិក្ខុ ហើយពោលថា លោកម្ចាស់ មានសេចក្ដីត្រូវការ ប៉ុនណា មេត្តាទទួលចុះ ។ ឈ្មោះថា ការនាំទៅចំពោះដោយបច្ច័យ ។

បទថា តត្រ ភិក្ខុ មត្តំ ន ជានាតិ (ភិក្ខុរមែងមិនស្គាល់ប្រមាណ

ក្នុង... នោះ) សេចក្តីថា ភិក្ខុរមែងមិនដឹងប្រមាណក្នុងបច្ច័យទាំងនោះ ។ អធិប្បាយថា ភិក្ខុមិនទទួលយកវត្ថុដែលគួរតាមប្រមាណ ដោយទំនងនេះ ថា គប្បីដឹងក្នុងទាយក គប្បីដឹងក្នុងទេយ្យធម៌ គប្បីជ្រាបកម្លាំងរបស់ខ្លួន ដូច្នេះ រមែងទទួលយកបច្ច័យដែលពួកទាយកនាំមកទាំងអស់ ។ មនុស្ស ទាំងឡាយទាស់ចិត្ត ទើបមិននាំមកបវារណាទៀត ។ ភិក្ខុនោះ កាល លំបាកដោយបច្ច័យទាំងឡាយ ទទួលកម្មដ្ឋានហើយ មិនអាចឲ្យចម្រើនបាន ។ល។ រមែងជាអ្នកឃ្លាតឆ្ងាយចាកព្រះធម៌ ។

បទថា តេ ន អតិរេកបូជាយ បូជេតា ហោតិ (រមែងមិនបូជា ភិក្ខុ... ដោយការបូជាដ៏ក្រៃលែង) សេចក្តីថា ភិក្ខុនោះ រមែងមិនបូជាភិក្ខុ ទាំងនោះដោយបូជាយ៉ាងក្រៃលែង ដែលមានកាយកម្មប្រកបដោយមេត្តា ជាដើម ទាំងក្នុងទីវាល និងទីកំបាំង ដូចជានាយគោបាលនោះ មិនលើក តម្កើងបូជាគោមេហ្វូង ។ តពីនោះ ព្រះថេរៈទាំងនោះគិតថា ភិក្ខុពួកនេះ មិនធ្វើនូវសេចក្តីគោរពកោតក្រែងក្នុងពួកយើង ទើបមិនសង្គ្រោះពួកភិក្ខុថ្មី ដោយការសង្គ្រោះ ២ យ៉ាង គឺ មិនសង្គ្រោះដោយធម្មសង្គហៈ ១ មិន

សង្គ្រោះដោយអាមិសសង្គហៈ ១ ។ រមែងសង្គ្រោះដោយអាមិសសង្គហៈ គឺ ដោយចីវរ ឬដោយអំបោះ ឬដោយវត្ថុដែលជាប់ដោយបាត្រ ឬដោយទីលំនៅ ។ ព្រះថេរៈទាំងនោះ រមែងមិនទំនុកបម្រុងភិក្ខុថ្មីទាំងឡាយ ដែលកំពុងលំបាក ស្គមស្លេកស្លាំង មិនឲ្យសិក្សាបាលី អដ្ឋកថា ពោល ឬតែងធម្មកថា ឬគម្ពីរដែលមានអត្ថកំបាំង ។ ភិក្ខុថ្មីទាំងឡាយ កាលមិនបានការសង្គ្រោះទាំងពីរយ៉ាងនោះ ឃ្លាតចាកសំណាក់ព្រះថេរៈទាំងឡាយដោយប្រការទាំងពួង រមែងមិនអាចតាំងនៅក្នុងព្រះសាសនានេះបាន រមែងមិនចម្រើនសីលក្ខន្ធជាដើម ដូចហ្វូងគោរបស់នាយគោបាលនោះ រមែងមិនលូតលាស់ចម្រើន ។ ភិក្ខុទាំងនោះ រមែងជាអ្នកត្រូវឃ្លាតឆ្ងាយចាកធម្មក្ខន្ធ ៥ ដូចនាយគោបាលនោះ ឃ្លាតចាកបញ្ចគោរស ដូច្នោះ ។ ធម៌ចំណែកស (កុសលធម៌) ក៏គប្បីជ្រាបការប្រកបសេចក្តី ដោយអំណាចសេចក្តីប្លែកគ្នាពីប្រការដែលពោលទុកហើយក្នុងធម៌ចំណែកខ្មៅ ។

ចប់អដ្ឋកថា គោបាលកសូត្រទី ៧

# អដ្ឋកថា បឋមសមាធិសូត្រទី ៨

*ពោលដោយការបានសមាធិ*

[១២៥] *ក្នុងសូត្រទី ៨ នេះ មិនមានសេចក្ដីកែរបស់អដ្ឋកថាទេ ។*

ចប់អដ្ឋកថា បឋមសមាធិសូត្រទី ៨

# អដ្ឋកថា ទុតិយសមាធិសូត្រទី ៩

*ពោលដោយការបានសមាធិ*

[១២៦] *ក្នុងសូត្រទី ៩ នេះ មិនមានសេចក្ដីកែរបស់អដ្ឋកថាទេ ។*

ចប់អដ្ឋកថា ទុតិយសមាធិសូត្រទី ៩

# អដ្ឋកថា តតិយសមាធិសូត្រទី ១០

*ពោលដោយការបានសមាធិ*

[១២៧] *ក្នុងសូត្រទី ១០ នេះ មិនមានសេចក្ដីកែរបស់អដ្ឋកថាទេ ។*

ចប់អដ្ឋកថា តតិយសមាធិសូត្រទី ១០

# អដ្ឋកថា ចតុត្ថសមាធិសូត្រទី ១១

*ពោលដោយការបានសមាធិ*

[១២៨] *ក្នុងសូត្រទី ១១ នេះ មិនមានសេចក្តីកែរបស់អដ្ឋកថាទេ ។ (ពាក្យដ៏សេសក្នុងវគ្គនេះ និងក្នុងព្រះសូត្រទាំងពួងក្រៅអំពីនេះ មានអត្ថងាយហើយ) ។*

ចប់អដ្ឋកថា ចតុត្ថសមាធិសូត្រទី ១១

## ចប់ទុតិយវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ០៧ សូត្រ

# ព្រះសូត្រមិនសង្គ្រោះក្នុងបណ្ណាសកៈ

*អង្គប្រកបរបស់នាយគោបាល ១១ ប្រការ*

*[១២៩-១៣០-១៣១-] ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាទេ ។*

# ពាក្យសរុបរបស់ព្រះអដ្ឋកថា

ដោយការពណ៌នាមកនេះ ខ្ញុំដែលព្រះជោតិបាលត្ថេរ អ្នកមានបញ្ញាល្អ ដែលធ្លាប់នៅរួមជាមួយខ្ញុំ ក្នុងក្រុងកញ្ចីបុរៈជាដើម បានអារាធនា សូម្បីក្នុងខណៈដែលនៅក្នុងមហាវិហារ នាលង្កាទ្វីប កាលព្រះសទ្ធម្មកំពុងទ្រុឌទ្រោម ដូចជាដើមឈើត្រូវព្យុះបោកបក់ ទាំងជីវកឧបាសក ដែលដល់ត្រើយសាគរ គឺ រៀនចប់ព្រះត្រៃបិដក អ្នកមានបញ្ញាល្អ អារាធនាហើយ ប្រាថ្នាសេចក្តីតាំងនៅនៃព្រះសាសនា ទើបផ្តើមតែងគម្ពីរអដ្ឋកថាណា នៃបាលីអង្គុត្តរនិកាយ ដែលវិចិត្រដោយលទ្ធិសម័យ ដែលព្រះធម្មកថិកទាំងឡាយដ៏ច្រើន ជាអ្នកល្អិតល្អន់សព្វគ្រប់ក្នុងន័យនៃធម្មកថា តែងចងក្រងទុកហើយ គម្ពីរអដ្ឋកថានេះ រក្សាសារៈសំខាន់របស់គម្ពីរមហាអដ្ឋកថា សម្រេចហើយ តែព្រោះហេតុមនោរថរបស់ខ្ញុំ ដែលនឹងអធិប្បាយនិកាយទាំងអស់ ដោយភាណវារៈនៃបាលីប្រមាណ ៩៤ ភាណវារៈ បរិបូរណ៌ហើយ អដ្ឋកថានោះ ទើបឈ្មោះថា មនោរថបូរណី តពីនោះ ព្រោះហេតុសូម្បីគម្ពីរវិសុទ្ធិមគ្គប្រមាណ ៥៩ ភាណវារៈ នៃមនោរថបូរណីនោះ ខ្ញុំក៏តែងដើម្បីប្រកាសអត្ថរបស់និកាយទាំងឡាយហើយ ដូច្នោះ អដ្ឋកថានេះនឹងគម្ពីរ

វិសុទ្ធិមគ្គនោះ គប្បីជ្រាបថា មាន ១៥៣ ភាណវារៈ តាមន័យនៃការរាប់គាថា អដ្ឋកថានេះ ប្រកាសលទ្ធិសម័យរបស់ព្រះថេរៈអ្នកនៅក្នុងមហាវិហារ ដោយភាណវារៈរាប់បាន ១៥៣ ភាណវារៈ ខ្ញុំអ្នកតែងគម្ពីរមនោរថបូរណីនេះ រក្សាសារៈសំខាន់នៃអដ្ឋកថាដើម សន្សំបុណ្យណានុក ដោយបុណ្យនោះ សូមសត្វលោកទាំងអស់ ចូរមានសេចក្តីសុខចុះ ។

ព្រះថេរៈ ដែលគ្រូទាំងឡាយថ្វាយនាមថា ពុទ្ធឃោសៈ អ្នកប្រដាប់ដោយសទ្ធា បដិភាណ សេចក្តីព្យាយាម ដ៏បរិសុទ្ធដ៏ក្រៃលែង អ្នកញ៉ាំងកំណើតគុណសមុទ័យ គឺ សីលអាចារៈនិងសេចក្តីស្មោះត្រង់ ទន់ភ្លន់ និងរឹងមាំ អ្នកអាចក្នុងការជម្រះគឺ លទ្ធិរបស់ខ្លួន និងលទ្ធិរបស់អ្នកដទៃ អ្នកប្រកបដោយប្រាជ្ញានិងសេចក្តីឆ្លាត អ្នកមានបដិភាណ គឺ ញាណដែលមិនទើសទាក់ក្នុងសត្ថុសាសន៍ ព្រមទាំងអដ្ឋកថា មានព្រះត្រៃបិដកបរិយត្តិ ជាអ្នកទ្រទ្រង់វេយ្យាករណ៍ធំ អ្នកប្រកបដោយគុណ គឺមានពាក្យពេជន៍ដ៏ពីរោះ ឱឡារ ថ្លៃថ្លាចាក្ខុរស្តាប់ ឲ្យកើតនូវករណសម្បត្តិ អ្នកមានវាទៈត្រឹមត្រូវបែកធ្លាយ ជាមហាកវីអ្នកសំនួនវោហារដ៏ពីរោះ ជាអលង្ការរបស់វង្សនៃព្រះថេរៈក្នុងមហាវិហារ អ្នកជាប្រទីបនៃថេរវង្ស ដែលមានប្រាជ្ញាតាំងមាំ

ល្អហើយ ក្នុងធម៌ដ៏ក្រៃលែងរបស់មនុស្ស ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ ជាដើម ដែលជាបរិវារនៃបដិសម្ភិទា ដែលបែកធ្លាយហើយ ជាអ្នកមានប្រាជ្ញាដ៏ទូលាយបរិសុទ្ធល្អ តែងអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះ មនោរថបូរណីគម្ពីរនេះ ។

សូមគម្ពីរអដ្ឋកថានេះសម្ដែងន័យ ដើម្បីសេចក្ដីបរិសុទ្ធនៃចិត្តរបស់ពួកកុលបុត្តអ្នកប្រាជ្ញាជួយលោក ចូរតាំងនៅក្នុងលោក ដ៏រាបស្មើនឹងព្រះនាមថា ពុទ្ធោ របស់ព្រះដ៏មានព្រះភាគទ្រង់មានចិត្តបរិសុទ្ធ ទ្រង់តាំងមាំ ទ្រង់ប្រសើរបំផុតក្នុងលោក ទ្រង់ស្វែងរកព្រះគុណដ៏ធំ ស្ថិតនៅហើយក្នុងលោកចុះ ។

ព្រះសូត្រ រួមហើយក្នុងគម្ពីរអង្គុត្តរនិកាយ

មាន ៩.៥៥៧ សូត្រ ដោយប្រការដូច្នេះ ។

## អដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះ មនោរថបូរណី

## ចប់ហើយ ដោយប្រការដូច្នេះ ។

# ចប់អដ្ឋកថា អង្គុត្តរនិកាយ

# ទសកនិបាត-ឯកាទសកនិបាត

# ឈ្មោះ

# មនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |